# កំណត់ហេតុរបស់ ជីវតាក្វាន់

## អំពីប្រពៃណីនៃអ្នកស្រុកចេនឡា

*digitized and check-spelled by Angkor Database, 2024*

**Translator Comments**

"The diary of Zhou Daguan (Chiv Takwan) about the traditions of the Chenla people" the reader is now holding is really a sacred document of our Khmer history. In every history book or any study on Cambodia, reference to Zhou Daguan's document was never omitted. The Cambodian youth who learns the history of their own country, will surely know the name: Chiv Ta Kwan, but what we do know are just consecutive words that was told from one to another, book copied after one another, from one book to another through the translation from the original book In French language by **Paul Pelliot** who translate from the Chinese article and was first published in the **Bulletin of the French School of the Far East (Bulletin de l'école française d'Extreme-Orient, BEFEO)** in 1902. After Pelliot's death, **George Cœdès** took his work, including additional commentary, to publish it as a book in 1951. Pelliot stated in his preface that he once had tried to translate from a document of Chiv Ta Kwan that **Abel Rémusat** has translate and had lunched the first publication in 1819 but not yet a perfection. **George Cœdès**, himself has been living in China for years until he can complete this work.

We, Khmer people would like to thank you especially for these researchers as their work is same as helping us to discover such a precious treasure. Because of those translators/researchers aren't Cambodian, we always thought that if any Cambodian can translate directly from the Chinese texts, we would feel more satisfied even though it is not a perfect translation.

I used to learn Chinese character for four years since I was young but had forgotten almost everything, only recalling some characters that I often used and can copy the Chinese texts. After seeing the translation of Pelliot including some Chinese texts along with explanations such as the name of the district and references of publications, I just kept noting down those detail as a document.

Fortunately, in 1962, I was given a cultural mission to lead a delegation of Cambodian writers to China. I always had a thought to ask for the document of Chiv Ta Kwan as I will be able to come to China, his home country. When I met with the Chinese minister of Culture, who was also the president of the **Chinese Writers Association**, I requested him to see Chiv Ta Kwan's writing with my desire to see and copy this document. The Minister of Culture agreed to fulfill my wish. That night, I was so excited and hoped for morning to arrive so I could go to visit their national library. I didn't get to go to the National Library the next morning, as we had a program to visit places far away from town first. It was not until five days later that I was taken to the **"rare book section"** in the National Library in Beijing. The librarian together with the other two collaborators - a librarian from the Rare Books section and **Tea Siv Meng**, 69, a specialist in researching the history of the Far East Countries, were waiting for me. Tea Siv Meng was the one who prepared a pile of books to show me, which are all related to the history of Cambodia and were all published from the 14th to the 17th centuries. We had a long conversation as he wanted to see if I really know and interested in the history or just asking in a way to show off. Fortunately, I have seen a lot of documents on the relationship between the two countries, and before coming to China, I also recorded these documents, because my mission is on this cultural issue. I answer to him in an agile response until the other party took me to meet the head of the history department.

Among those thick books, some only describe about our country in only a few pages. An only one book called **"The History of the Mongolian Empire"** which has a large part that was briefly describing about sending a missionary, Chiv Ta Kwan to Chenla. I asked to copy this whole book, 63 pages, and they agreed to let me copy, resulting in a big file of pictures. After arriving back in Cambodia, I printed out the photos but unfortunately, they weren't clear enough to understand the letters on it. I gathered all of the printed photos, compiled them as a book, and kept it at the **Khmer Writers Association**, hoping that in the future, someone may be able to translate it. Two years later, the book was lost and no one knew where it was or who took it. I assumed that the person who took the book must had deliberately taken it to keep as their own, or to hid it to prevent anybody from translating the article. Luckily, I still had another file of the photos I took back then in China and printed out, translated and published. Even though, it was not perfect but it helps to contribute to the work of Cambodian researchers. Secondly, it also adds to the number of useful information.

This translation work had me worried as I have to find someone who can translate Chinese texts and ancient Chinese texts. However, we couldn't find anyone with sufficient knowledge to do so. Most of the translators only have sufficient knowledge to translate modern Chinese texts, but not ancient Chinese texts. One of my friends, **Eung Lay** was a writer in **1955-1956**, then a translator and subtitler for Chinese films, was able to translate old Chinese texts. He promised to gives his full support and we did translate the whole book. When there are difficult words, he checks the dictionary and write a note with the definition for me. My other friend, **Ma Eang** used to be a Khmer literature teacher at a Chinese school also have helped me to translate some part of the book. I put together the two translated works and compared the original text to the one we have translated, and also to Pelliot's French translation. This was still unsatisfied for me. One day, I ran into my former teacher, **Tang Suy Kong**, who's now 71 years of age. When I was learning

Chinese in 1940, he was a professor of Khmer literature. He knew many stories and was self-taught, following traditional Chinese methods. Currently, he lives with his children and grandchildren, some of whom work as civil servants while others are involved in business. I asked him to help me verifying the meaning. He was happy to help with the translation. He then explained me chapter by chapter, with me attempting to verify the meaning of my translation, adding any missing part, amending wrong spelling, adding clarification notes to the most difficult to understand parts, always following what he told me. After three months, we finalized the piece nd published it.

On the other hand, there are different tones in the Chinese language, depending on the dialects, such as Beijing, Shanghai, Cantonese, Teochew, and Hokkien. Chiv Ta Kwan was born in **Wenzhou**, southeast of China. Therefore, his language is very special, just like his hometown. In Chenla, there are no Chinese from Wenzhou, only those from Kwang Tung, known as Cantonese or Teochew, who have settled and been living in Chenla. That is why the accent of the words he tried to replicate from Khmer was very difficult to understand, partly due to the Cantonese or Teochew accents of the Chinese translators who assisted him. In this translation, we agreed to follow the Teochew accent as the primary one because the Teochew community has the largest population living in Chenla and most of the people who speak Chinese or the Khmer words translated from Chinese pronounce them according to the Teochew accent.

Therefore, I would like to apologize in advance to those of you who have a deep understanding of Chinese if my team and I have made any omissions, or if there are any gaps in our transcription.

**Phnom Penh. June, 1971**
**Ly Theam TENG**

## កំណត់ហេតុរបស់ ជីវតាក្វាន់

## ប្រពៃណីអ្នកស្រុកចេនឡា

### យោបល់អ្នកបកប្រែ

**“កំណត់ហេតុរបស់ ជីវ តាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា”** ដែលមិត្តអ្នកអានកំពុងកាន់នៅដៃនេះ ពិតជាឯកសារពិសិដ្ឋមួយនៃប្រវត្តិសាស្ត្រខ្មែរយើង។ សៀវភៅប្រវត្តិវិទ្យាឬអត្ថបទសិក្សាណាមួយដែលស្តីពីស្រុកខ្មែរ មិនដែលចន្លោះឈ្មោះឯកសារជីវ តាក្វាន់ នេះឡើយ។ កូនខ្មែរគ្រប់រូប រៀនប្រវត្តិប្រទេសខ្លួន មិនដែលនរណាមួយមិនស្គាល់ឈ្មោះជីវ តាក្វាន់ដែរ ប៉ុន្តែការដែលយើងស្គាល់នោះ សុទ្ធតែពាក្យតៗគ្នា កត់ចម្លងតៗគ្នាពីសៀវភៅមួយទៅសៀវភៅមួយ តាមរយៈសៀវភៅដើមជាភាសាបារាំងដែលលោក **ប៉ូលប៉េលីយ៉ូ** បានប្រែសម្រួលចេញពីអត្ថបទចិន ហើយបោះពុម្ពផ្សាយដំបូងនៅក្នុងព្រឹត្តិប័ត្រនៃសាលាបារាំងនៅចុងបូព៌ា = **Bulletin de l'école française d'Extreme-Orient (BEFEO)** ពីឆ្នាំ **១៩០២** ហើយក្រោយមក ពេលដែលលោកប៉េល្លីយ៉ូ ទទួលមរណភាពទៅ លោក **ហ្សក សឺដេស** ក៏យកស្នាដៃនេះមានទាំងអត្ថាធិប្បាយបន្ថែមក្បោះក្បាយផង ទៅបោះពុម្ពរួបរួមជាសៀវភៅមួយឡើងពី**គ.ស.១៩៥១**។ លោក ប៉េល្លីយ៉ូ បានបញ្ជាក់ក្នុងអារម្ភកថាថា៖ លោកបានព្យាយាមបកប្រែតាមការស្រាវជ្រាវរកឯកសាររបស់ ជីវ តាក្វាន់ ដែលមានលោក **អាប់បែល រ៉េមុសាត់** បាន ប្រែផ្សាយម្តងហើយពី **គ.ស. ១៨១៩** ប៉ុន្តែមិនទាន់គ្រប់សព្វ។ ខ្លួនលោកបានទៅនៅប្រទេសចិនអស់ច្រើនឆ្នាំទើបប្រែបានជាស្នាដៃនេះ។

យើងជាខ្មែរ យើងសូមគោរព អរគុណពិសេសចំពោះលោកអ្នកស្រាវជ្រាវជំនាញទាំងនេះ ទុកដូចជាជួយរើកកាយកំណប់ដ៏មានតម្លៃមួយឲ្យយើងដែរ។ ប៉ុន្តែ ដោយលោកអ្នកប្រែនោះឯង មិនមែនជាខ្មែរ ម្ល៉ោះហើយយើងចេះតែមានចិត្តតូចមួយមមៃនឹកជានិច្ចថា ប្រសិនជាខ្មែរណាប្រែចេញពីអត្ថបទភាសាចិនផ្ទាល់តែម្តង យើងដូចជាអស់ចិត្តជាង ទោះបីការបកប្រែនោះមិនជ្រៅជ្រះឆ្អិនឆ្អៅណាស់ណាក៏ដោយ។

ខ្ញុំធ្លាប់បានរៀនអក្សរចិនអស់បួនឆ្នាំកាលនៅពីក្មេង តែភ្លេចភ្លាំងទៅវិញស្ទើរគ្មានសល់ នៅចាំបាននៅតែតួអក្សរណាធ្លាប់ប្រើញឹកញាប់និងនៅចេះសរសេរចម្លងតាមគេកើត។ លុះដល់ឃើញសេចក្តីប្រែរបស់លោក ប៉េល្លីយ៉ូ មានស្រង់ទាំងពាក្យ ទាំងអក្សរចិនមកបញ្ជាក់ផង ដូចជាឈ្មោះស្រុក ឈ្មោះរបស់ ឈ្មោះការផ្សាយជាដើម ខ្ញុំក៏ចេះតែកត់ទុកៗ នូវអក្សរចិនទាំងនោះគ្រាន់ជាឯកសារ។

សំណាងមាន នៅឆ្នាំ **១៩៦២** ខ្ញុំបានទទួលបេសកកម្មមួយខាងវប្បធម៌ ឲ្យខ្ញុំដឹកនាំគណៈប្រតិភូអ្នកនិពន្ធខ្មែរ ទៅកាន់ប្រទេសចិន។ ខ្ញុំនឹកជាប់ក្នុងចិត្តជានិច្ចថា ក្នុងដំណើរនេះ ខ្ញុំនឹងសាកសួរគេរកឯកសារស្នាដៃ ជីវ តាក្វាន់ ឲ្យបានឃើញផ្ទាល់ភ្នែកតែម្តងបំណាច់បានមកជាន់ដីស្រុកកំណើតជីវ តាក្វាន់ ហើយ។ នៅពេលដែលខ្ញុំជួបសន្ទនាជាមួយនឹងរដ្ឋមន្ត្រីក្រសួងវប្បធម៌ចិនដែលកាលនោះជាប្រធានសមាគមអ្នកនិពន្ធចិនផងនោះ ខ្ញុំបានស្នើនឹងគេអំពីបំណងចង់ឃើញនិងចង់ចម្លងឯកសារ ជីវ តាក្វាន់នេះ។ រដ្ឋមន្ត្រីវប្បធម៌នោះឯង ទទួលរ៉ាប់រងបំពេញបំណងខ្ញុំ។ យប់នោះ ខ្ញុំអរក្រៃលែង អរបន់ឲ្យតែភ្លឺឆាប់នឹងបានទៅទស្សនា បណ្ណាល័យជាតិរបស់គេ តែមិនទាន់បានទៅភ្លាមទេ ព្រោះមានកម្មវិធីទៅទស្សនាទីឆ្ងាយៗ ពីនេះសិន។ ទាល់តែប្រាំថ្ងៃក្រោយមកទើបគេនាំខ្ញុំទៅកាន់ទីទុកឯកសារនេះ ដែលគេហៅថា **“ផ្នែកខាងសៀវភៅកម្រ”** ស្ថិតនៅក្នុងបណ្ណាល័យជាតិក្រុងប៉េកាំង។ នាយបណ្ណាល័យនាំសហការីគេពីរនាក់ទៀតនៅរង់ចាំខ្ញុំ គឺ**នាយផ្នែកខាងសៀវភៅកម្រ** និង**អ្នកឯកទេសខាងការស្រាវជ្រាវប្រវត្តិចុងបូព៌ាប្រទេស**ឈ្មោះ **ទា ស៊ីវម៉េង** អាយុ ៦៩ ឆ្នាំ។ គឺលោក ទា ស៊ីវម៉េង នេះហើយដែលបានរើសៀវភៅក្រាស់ៗ មួយគំនរ មកចាំបង្ហាញខ្ញុំ ដែលសុទ្ធសឹងជាសៀវភៅមានស្តីទាក់ទងនឹងប្រវត្តិស្រុក ខ្មែរ ហើយសុទ្ធតែសៀវភៅដែលបោះពុម្ពតាំងពី**សតវត្សទី ១៤-១៥-១៦ និង ១៧** មកម្ល៉េះ។ គេសន្ទនានឹងខ្ញុំយ៉ាងច្រើន ហាក់ដូចជាចង់ល្បងថាតើខ្ញុំទទូចរកឯកសារនេះ ជាអ្នកចេះដឹងខាងប្រវត្តិស្រុកទេសមែនទែន ឬក៏គ្រាន់តែរកៗទៅទេ? ជាភ័ព្វល្អ ខ្ញុំធ្លាប់បានមើលឯកសារច្រើនស្តីពីការទាក់ទងរវាង ស្រុកទាំងពីរនេះ ហើយមុននឹងទៅស្រុកគេ ក៏ខ្ញុំបានកត់ត្រាឯកសារនេះច្បាស់ៗទៀត ព្រោះបេសកកម្មខ្ញុំចំលើរឿងវប្បធម៌នេះឯងផង ម្ល៉ោះហើយ ខ្ញុំឆ្លើយជាមួយគេរហ័សរហួនណាស់ រហូតគូសន្ទនាទាំងបីនាក់នោះ នាំខ្ញុំទៅជួបនឹងបណ្ឌិតសភាខាងប្រវត្តិសាស្ត្រទៀត ។

ក្នុងបណ្តាសៀវភៅក្រាស់ៗទាំងនោះមានខ្លះនិយាយពីស្រុកយើងតែ១ ឬ២ទំព័រប៉ុណ្ណោះទេ មានតែមួយប៉ុណ្ណោះដែលមានសេចក្តីវែងក្បោះក្បាយ គឺ**ប្រវត្តិក្នុងរាជសន្តតិវង្សម៉ុងហ្គោល** ដែលមានមួយភាគធំនិយាយពីការចាត់អ្នកកត់ត្រាមកស្រុកចេនឡាគឺលោក ជីវ តាក្វាន់នេះឯង។ ខ្ញុំសុំចម្លងអត្ថបទនេះទាំងស្រុងដែលមានចំនួន **៦៣ទំព័រ** គេក៏ព្រមថតចម្លងឲ្យខ្ញុំ បានជាហ្វីលមួយខ្សែវែង។ លុះមកដល់ស្រុកវិញ ខ្ញុំផ្តិតចេញជាសន្លឹកអក្សរហើយ តែអនិច្ចា! នៅតែអង្គុយមើលៗ វាយសេចក្តីមិនបែកសោះ។ ខ្ញុំបានយកអក្សរថតផ្តិតនេះ បិទធ្វើជាសៀវភៅមួយ ហើយយកទៅតម្កល់ទុកនៅ**សមាគមអ្នកនិពន្ធខ្មែរ** ព្រោះសង្ឃឹមក្រែងថ្ងៃក្រោយមានលោកណាមួយក្នុងបណ្តាអ្នកនិពន្ធអ្នកស្រាវជ្រាវ អាចធ្វើការបកប្រែអត្ថបទនេះបាន។ ស្រាប់តែពីរឆ្នាំក្រោយមក បាត់សៀវភៅនោះជាអាសារបង់ទៅ សួររកដើមចុងមិនឃើញ ខ្ញុំក៏នឹកថា៖ អ្នកដែលឆ្លៀតបំបាត់សៀវភៅនេះ ពិតជាមានបំណងយកទៅធ្វើឯកសារផ្ទាល់ ឬមួយលាក់កំបាំងកុំឲ្យយើងធ្វើការបកប្រែបាន។ តែជាសំណាងល្អ ខ្ញុំនៅសល់ហ្វីល ក៏ផ្តិតបានមួយច្បាប់ទៀត ហើយក៏ចាត់ចែងបកប្រែ បោះពុម្ពឲ្យបាន ទោះមិនទាន់ល្អហ្មត់ចត់ ក៏បានជាផ្លូវសម្រាប់អ្នកសិក្សា អ្នកស្រាវជ្រាវមួយផ្នែកធំដែរ។ មួយទៀត សម្រាប់អ្នកសិក្សាបានជាប្រភពមួយទៀត ប្រៀបធៀបនឹងប្រភពដទៃៗផង។

ការបកប្រែនេះបានធ្វើទុក្ខខ្ញុំយ៉ាងខ្លាំង ព្រោះខ្ញុំត្រូវការពឹងរកអ្នកចេះអក្សរចិន ហើយរបៀបចិនបុរាណទៀត ឯអ្នកចេះចិនសម័យថ្មី អានមិនយល់ច្បាស់ វាយសេចក្តីពុំបានន័យឡើយ។ មិត្តខ្ញុំម្នាក់ឈ្មោះ **អ៊ឹង ឡាយ** ជាអ្នកនិពន្ធ ប្រលោមលោកច្រើនរឿងដែរតាំងពីឆ្នាំ **១៩៥៥-៥៦** ហើយតមកគាត់ជាអ្នកឯកទេសប្រែរឿងភាពយន្តចិន ទោះជារឿងបុរាណ ដែលប្រើពាក្យជំនាន់ចាស់ៗ ក៏គាត់ធ្លាប់ជួបប្រទះគ្មានសល់។ មិត្ត អ៊ឹង ឡាយ បានធានាជួយខ្ញុំពេញកម្លាំង។ លោកប្រែអត្ថបទនេះមួយចប់ឲ្យខ្ញុំ ហើយត្រង់ពាក្យណាពិបាកពេកគាត់ដេញសួរទៅវចនានុក្រមចិន ហើយកត់ទាំងពាក្យពន្យល់ទុកឲ្យខ្ញុំផង។ មានមិត្តខ្ញុំម្នាក់ទៀតឈ្មោះ **ម៉ា អៀង** ធ្លាប់ធ្វើជាគ្រូបង្រៀនអក្សរខ្មែរនៅសាលាចិន ក៏បានជួយបកប្រែខ្ញុំមួយចំណែកផ្សេងទៀតដោយអន្លើខ្លះ មិនបានចប់ចុងចប់ដើមទេ។ ខ្ញុំយកសំណៅបកប្រែទាំងពីរនេះមកមើលសម្រួលកែកុនផ្សំបញ្ចូលគ្នាដោយផ្ទៀងខ្លះជាមួយអក្សរចិនជាអត្ថបទដើម ដែលខ្ញុំអាចមើល

បានដោយអន្លើៗ ផ្សែផ្សំផង ហើយខ្ញុំផ្ទៀងជាមួយនឹងស្នាដៃប្រែរបស់លោក ប៉េលីយ៉ូ ជាភាសាបារាំងទៀត។ ប៉ុន្តែនៅតែមិនអស់ចិត្ត។ លុះថ្ងៃមួយ ខ្ញុំជួបគ្រូចាស់ខ្ញុំដែលឥឡូវអាយុ៧១ឆ្នាំហើយ ឈ្មោះលោក **តាំងស៊ុយគង់**។កាលខ្ញុំរៀនអក្សរចិន (១៩៤០) លោកជាសាស្ត្រាចារ្យខាងអក្សរសាស្ត្រ ធ្លាប់ចេះចាំរឿងព្រេងសព្វគ្រប់ ជាអ្នកសិក្សាដោយខ្លួនឯង តាមរបៀបចិនបុរាណ។ ឥឡូវលោករស់នៅជាមួយកូនចៅដែលសុទ្ធសឹងជាមន្ត្រីរដ្ឋការយើងខ្លះ និងខ្លះជាអ្នកជំនួញ។ ខ្ញុំស្នើសុំឲ្យគាត់ជួយផ្ទៀងជាមួយខ្ញុំ។ លោកតាទទួលដោយរីករាយពេញចិត្តនិងកិច្ចការនេះដូចមិត្តខ្ញុំទាំងពីរខាងលើដែរ។ គាត់ពន្យល់ខ្ញុំម្តងមួយវគ្គៗ ខ្ញុំផ្ទៀងមើលតើត្រូវន័យសព្វគ្រប់ដូចសេចក្តីប្រែរបស់ខ្ញុំឬទេ បើខ្វះខ្ញុំក៏បន្ថែម បើមិនងាយយល់ ខ្ញុំក៏ធ្វើន័យលក្ខណៈ ពន្យល់ខាងក្រោមតាមគាត់ប្រាប់។ អស់រយៈបីខែទៀត ទើបបានសម្រេចយកសេចក្តីបានប៉ុនដែលចាត់ការបោះពុម្ពពេលនេះ ។

ម្យ៉ាងទៀត អំពីសំនៀងភាសាចិន មានច្រើនយ៉ាងតាមក្រាមភាសា (dialectes) ដូចជាភាសា ប៉េកាំង ស៊ាងហៃ កន្តាំង ទាជីវ ហុកគៀន។ល។ ខ្ញុំសុំបញ្ជាក់ថាលោកជីវ តាក្វាន់ មានកំណើតនៅ**វ៉េងគា ខេត្រជាក់កាង** ក្នុង**ភូមិភាគចិនខាងត្បូង**។ ដូច្នេះសម្តីភាសាលោកក៏ពិសេសតាមស្រុកនោះដែរ។ តែមកដល់ប្រទេសចេនឡាគ្មានចិនស្រុកគាត់មកនៅទេ មានតែចិន**ខេត្រគង់ទុង ឬក្វាង តាំង** ខ្មែរយើងធ្លាប់ហៅ**ចិនកន្តាំង ចិនទាជីវ**នេះឯងមករស់នៅ។ ម្លោះហើយសម្លេងពាក្យដែលគាត់ប្រែពីខ្មែរទៅពិបាកស្តាប់ណាស់ ព្រោះតាមសំនៀងពួកកន្តាំងនិងទាជីវជាអ្នកប្រែឲ្យគាត់ផងនិងតាមសំនៀងភាសាផ្ទាល់របស់ស្រុកកំណើតគាត់ផង។ ក្នុងការបកប្រែនេះ យើងខ្ញុំសម្រេចគ្នាថាយកតាមសំនៀងចិនទាជីវជាគោលព្រោះមានតែចិនទាជីវទេ ដែលរស់នៅភាគច្រើនលើសលុបគេក្នុងស្រុកខ្មែរ ហើយអ្នកចេះភាសាចិនឬក៏ពាក្យខ្មែរខ្លះដែលក្លាយមកពីចិនក៏សុទ្ធតែអានតាមសំនៀងចិនទាជីវទាំងអស់ ។

ដូច្នេះខ្ញុំសុំអភ័យទោសជាមុនពីសំណាក់លោក-អ្នកដែលចេះចិនជ្រៅជ្រះ ក្រែងលោខ្ញុំនិងគ្នីគ្នាខ្ញុំ ផ្សំគ្នាប្រែនេះមិនទាន់សព្វគ្រប់ ខ្វះចន្លោះពាក្យពេចន៍ ។

ភ្នំពេញ ខែមិថុនា គ.ស. ១៩៧១

**លី ធាមតេង**

## សេចក្តីផ្តើម

រឿងរ៉ាវទាំងនេះ **លោក ជីវ តាក់គង់**[១] បាននិពន្ធឡើងក្នុងសម័យរាជសន្តតិវង្ស ងន់[២] គឺនៅស្រុកវ៉េងតា[៣] ហើយក្រោយមក លោក ហ្គូវ គង់ បានកែសម្រួលក្នុងរវាងរាជសន្តតិវង្ស ម៉េង[៤] ក្នុងស្រុកសេងអាន[៥]។

សេចក្តីអធិប្បាយទាំងស្រុងមានដូចតទៅៈ

ចេនឡា ឬ ចាមឡា អ្នកប្រទេសនេះហៅខ្លួនឯងថា **កាន់ផៃចី** តាមកំណត់ខ្លះរបស់ពួកបស្ចិមប្រទេសបានហៅថា កាំពូចី ដែលមានសម្លេងស្រដៀងនឹង "កាំពួចេ" ដែរ។

ខ្ញុំចាប់ធ្វើដំណើរចេញពីស្រុកអ៊ូជីវ[៦] តាមផ្លូវទឹក តាមទន្លេស្រុកម៉ាំងគូយនិងគង់តុង កាត់សមុទ្រ " ឈិតជីវ " ទៅ ដល់សមុទ្រ " ការជីវ " ក៏បានទៅដល់ទីក្រុង"ចាម្ប" បន្តដំណើរបណ្តោយខ្យល់ចេញពីក្រុង "ចាម្ប" ទៅអស់រយៈពេលកន្លះខែទៀតក៏បានទៅដល់ស្រុក ចេងផូវ (ជម្ពូ?) ដែលជាព្រំដែននៃប្រទេសនេះ។ លុះចេញពីចេងផូវទៅទៀត ឆ្លងផុតសមុទ្រឃុនលុន ក៏ដល់ទៅមាត់ពាម គឺបែកចេញពីមាត់សមុទ្រទៅជាដៃទន្លេច្រើនច្រកណាស់។ ក្នុងបណ្តាច្រកទាំងនោះ មានតែច្រកទី៤ ទេ ទើបអាចចូលទៅបាន ក្រៅពីនេះគេដឹងថាមានទឹករាក់ណាស់ នាវាធំៗមិនអាចធ្វើដំណើរបានឡើយ។ ត្រង់ពាមជាមាត់ច្រកនោះ ឃើញមានព្រៃស៊ុបទ្រុបហើយក្រៅពីនេះមានវាលខ្សាច់ពណ៌លឿងនិងមានដើមបបូសនិងអំពៅព្រៃដុះបែកផ្កាសសំព្រូស ម្ល៉ោះហើយអ្នកដំណើរពិបាកចំណាំផ្លូវរកច្រកចូលទៅណាស់។

ចូលផុតពីមាត់ពាម ធ្វើដំណើរតាមដងទន្លេឆ្ពោះទៅទិសខាងជើងអស់រយៈដំណើរប្រមាណកន្លះខែទៀត ទើបបានទៅដល់ស្រុកមួយឈ្មោះ ឆេណាំ (ឆ្នាំង?) ដែលជាខែត្រមួយនៃប្រទេសនេះ។ លុះធ្វើដំណើរពីឆេណាំ បណ្តោយតាមទឹកហូរទៅជើង អស់ពេល ១០ ថ្ងៃទៀត កាត់ភូមិពូឡូវឈឹង (ប្រែថាភូមិកណ្តាលផ្លូវ) ហ៊ុតឈឹង (ភូមិព្រះពុទ្ធ)[៧] ឆ្លងកាត់សមុទ្រទឹកសាប[៨]ទៅទៀត ទើបបានដល់ទីក្រុងកាងពាងឈូ (កំពែងជួរ?)។ ក្រុងនេះ មានទំហំ ៥០ លី (១លីប្រវែង ១. ៨០០ ហត្ថ) បើតាមសៀវភៅពួកបស្ចិមប្រទេសសរសេរថា ប្រទេសនេះ មានទំហំដី ៧.០០០ លី និងមានព្រំប្រទល់ខាងជើងទល់នឹងក្រុងចាម៉្ប៉ា គឺត្រូវធ្វើដំណើរអស់ពេលកន្លះខែ ខាងនិរតីនៅឃ្លាតពីស្រុកសៀមចម្ងាយផ្លូវកន្លះខែដែរ នៅខាងត្បូងឃ្លាតពីទីក្រុង **ហួងអ៊ូ** ចម្ងាយផ្លូវ ១០ ថ្ងៃ ឯខាងកើតប្រទេសនេះគឺមហាសមុទ្រ ហើយដែលជាប្រទេសមួយធ្លាប់ទាក់ទងខាងសេដ្ឋកិច្ចជាមួយស្រុកយើង តាំងពីដើមរៀងមកផង។

នៅគ្រាដែលប្រទេសចិន(ក្នុងរាជ្យសន្តតិវង្សម៉ុងហ្គោល) បានត្រួតត្រាលើមហាសមុទ្រក្នុងទ្វីបលោកហើយ លោក ចមពល (មេទ័ពធំ )ឈ្មោះ ដុន តូវ ដែលនៅឈរប្រចាំការត្រួតត្រាទីក្រុងចាម្ប បានចាត់មន្ត្រីពីរនាក់គឺលោក ហ៊្វូ-ប៉េក ហូវ អ្នកមានប៉ានមាស ១ និងលោក ឆាយ-ហូវ ៩ទៅកាន់ប្រទេសចេនឡា តែត្រូវប្រទេសនេះចាប់ឃុំទុកមិនឲ្យមកវិញ។ លុះមកដល់រជ្ជកាលស្តេច ងន់ ចេង (គ.ស. ១២៩២) ខែទី ៦ ព្រះរាជាអង្គនេះ ទ្រង់ចាត់បេសកកម្មទូតមួយមកប្រទេសចេនឡា ហើយពេលនោះខ្លួនខ្ញុំក៏ត្រូវចាត់មកជាមួយដែរ។ គឺនៅក្នុងខែទី ២ នៃឆ្នាំបន្ទាប់មក យើងបានចាកចេញពីស្រុក ម៉េងជីវ នោះមកទៀត។ លុះថ្ងៃ ១៥ ខែទី ៣ ទើបដល់ទីក្រុងចាម្ប។ នៅកណ្តាលផ្លូវជួប នឹងខ្យល់បក់បញ្ច្រាសពីមុខបកវិញ ដែលជាហេតុនាំឱ្យមានការរអាក់រអួលក្នុងដំណើរ។ ដល់មកខែ៧ ដែលជាសរទរដូវ ទើបបានមកដល់ប្រទេសនេះ ព្រមចំណុះចុះចូលទៅ[៩]។

លុះដល់មករជ្ជកាលស្តេច **តាយ តេក** (គ.ស ១២៩៧) ខែទី ៦ ខ្ញុំជិះនាវាត្រឡប់មកវិញ ហើយដល់ថ្ងៃ ១២ ខែ៨ ទើបនាវាចូលចតដល់កំពង់ផែស្រុកស៊ីម៉េង។

ចំពោះរឿងប្រពៃណីនិងកិច្ចការនៃប្រទេសចេនឡានេះ ខ្ញុំមិនបានដឹងល្អិតល្អន់អស់សេចក្តីសព្វគ្រប់មែន តែខ្ញុំបានដឹងដោយត្រួសៗអាចនឹងជម្រាបបានដែរ។

## ១. បរិវេណនៃទីក្រុង

បរិវេណនៃទីក្រុងនេះមានទំហំ ២០ លី មានទ្វារ ៥។ ទ្វារទាំងនោះ សុទ្ធតែសាងកម្រាស់ជាពីរជាន់ក្នុងក្រៅ គឺនៅទិសខាងកើតមានទ្វារពីរ។ ក្រៅពីនេះ ក្នុងមួយទិសមានទ្វារតែមួយទេ។ នៅក្រៅកំពែងក្រុង សុទ្ធតែមានប្រឡាយទឹកធំៗ ពីក្រៅប្រឡាយនោះ មានផ្លូវដើរទៅកាន់ស្ពានធំៗ ហើយនៅសងខាងស្ពាននីមួយៗ មានទេវរូបថ្ម ៥៤ ដូចជារូបមេទ័ពថ្មដ៏ធំៗដូច្នេះដែរ។ រូបទាំងនោះដូចៗគ្នានៅតាមច្រកទាំងប្រាំ។ បង្កាន់ដៃស្ពានទាំងនេះគេធ្វើអំពីថ្ម ហើយមានឆ្លាក់ជារូបពស់ដ៏ធំ[១០] ដែលមានក្បាល ៩ ឯរូបថ្មទាំង ៥៤ នោះសុទ្ធតែយកដៃចាប់ទាញពស់នេះឯងហាក់ដូចជាមិនចង់ឲ្យស្ទុះទៅរួច។ នៅខាងលើខ្លោងទ្វារ មានពុទ្ធរូបថ្មប្រាំអង្គបែរភ័ក្ត្រទៅទិសខាងលិច ហើយមួយអង្គដែលស្ថិតនៅចំកណ្តាលគេ មានទីបមាសល្អស្រស់ផង។ នៅសងខាងទ្វារ មានឆ្លាក់រូបដំរីថ្មទៀត។

កំពែងទីក្រុង គេធ្វើពីថ្មទាំងអស់ មានកំពស់ ២០ ហត្ថ តម្រៀបថ្មយ៉ាងជិតហើយមាំណាស់។ នៅពីលើគ្មានស្មៅដុះឡើយ តែនៅចន្លោះមួយដុំៗ មានដាំដើមជ្រៃ។ ឯផ្ទៃក្នុងនៃកំពែង ដែលមានចន្លោះពីគ្នាដល់ទៅជាង ១០០ ហត្ថ នោះ ស្ថិតនៅជាដីជម្រាលបីដូចជម្រាលនៃភ្នំ រលីងស្អាតណាស់។ លើកំពែងដែលមានផ្ទៃជាដីជម្រាលនោះ មានទ្វារធំៗ ដែលបិទជិតនៅពេលយប់ ហើយបើកចំហនៅពេលថ្ងៃតាំងពីព្រលឹមនិងមានអ្នកយាមប្រចាំការជានិច្ច។ សត្វឆ្កែ គេមិនឲ្យចូលក្នុងទ្វារនេះទេ។ ជនណាដែលធ្លាប់មានទោស ត្រូវគេកាត់ម្រាមជើង ក៏មិនឲ្យចូលដែរ។ កំពែងព័ទ្ធជុំវិញនោះ មានជ្រុងជ្រោយល្អណាស់ ហើយនៅត្រង់ជ្រុងនីមួយៗ សឹងមានប្រាង្គថ្មមួយខ្ពស់នៅប្រចាំគ្រប់ជ្រុង។

នៅកណ្តាលទីក្រុងនេះ មានប្រាសាទមាសមួយ[១១] និងនៅជិតខាងនេះមានប្រាង្គប្រាសាទជាង ២០ ទៀត ព្រមទាំង មានបន្ទប់ថ្មចំនួនច្រើនរយបន្ទប់ផង។ នៅប៉ែកខាងកើតមាន ស្ពានមាសមួយ មានរូបគោមាស ២ ស្ថិតនៅអមខាងឆ្វេងនិង ខាងស្តាំស្ពានមាស។ មានព្រះពុទ្ធរូបមាស ៨ អង្គ តម្កល់ នៅតម្រៀបគ្នាចំពីក្រោមប្រាង្គសិលា។ នៅខាងជើងប្រាសាទមាសចម្ងាយប្រមាណជាងមួយលីមានប្រាសាទស្ពាន់មួយទៀតដែលមានកំពស់ខ្ពស់ជាងប្រាសាទមាស គួរឲ្យគេគយគន់ណាស់។ ចំពីក្រោមប្រាសាទស្ពាន់នេះ ឃើញមានបន្ទប់ថ្មប្រហែលជាដប់ដែរ។ ចេញពីនេះទៅខាងជើង ថែមមួយលីទៀត គឺជាព្រះរាជដំណាក់ដែល ស្តេចគង់នៅ។ នៅក្នុងល្វែងដែលជាព្រះដំណាក់នោះ មានប្រាង្គមាសមួយទៀត។ ទំនងជាដោយហេតុនេះហើយ ដែលពួកឈ្មួញបរទេសតែងដំណាលថា ប្រទេសចេនឡា ថ្កុំថ្កើងរុងរឿងណាស់។

ចេញពីកំពែងតាមទ្វារខាងត្បូងទៅ ចម្ងាយប្រមាណជាជាងកន្លះលី តាមពាក្យចចាមអារាមគេនិយាយថាមានចេតិយ លូប៉ូន[១២] សង់តែមួយយប់។ ផ្នូរសពឬចេតិយ លូប៉ូន ស្ថិតនៅ ក្រៅកំពែងខាងត្បូងជាងកន្លះលី ហើយមានបរិវេណព័ទ្ធជុំវិញប្រមាណជាងដប់លី និងមានបន្ទប់ថ្មជាច្រើនរយទៀតផង។ នៅស្រះខាងកើតកំពែងនគរ ប្រមាណចម្ងាយដប់លី មាន ប្រាសាទថ្មីមួយទៀត[១៣]ក៏មាន

បរិវេណព័ទ្ធជុំវិញប្រវែង ១០០ លី។ នៅក្នុងប្រាសាទនេះ មានព្រះពុទ្ធរូបមួយអង្គទ្រង់ផ្ដុំពីស្ពាន់ ហើយមានទឹកចេញជានិច្ចពីត្រង់ផ្ចិត ហូរធ្លាក់ទៅក្នុងស្រះធំមួយនៅពីខាងជើងប្រាសាទនេះ។ នៅទិសខាង ជើងកំពែងនគរ ចម្ងាយប្រមាណ ៥ លី មានប្រាសាទមាសរាងបួនជ្រុង[១៤] និងមានបន្ទប់ថ្មជាច្រើនរយ ហើយនៅក្នុង នោះគេឃើញមានព្រះពុទ្ធរូបមាស រូបសឹង្ហមាស រូបដំរី រូបគោ រូបសេះនិងវត្ថុដទៃទៀតធ្វើពីស្ពាន់ ច្រើនឥតគណនា។

## ២. ដំណាក់-លំនៅឋាន

ព្រះដំណាក់ ផ្ទះនាម៉ឺនមន្ត្រី និងផ្ទះអ្នកមានទាំងអស់សុទ្ធតែបែរមុខទៅកើត។ ព្រះរាជដំណាក់ ស្ថិតនៅខាងជើង ប្រាសាទមាស និងស្ពានមាស ហើយនៅជិតមាត់ទ្វារក៏មានបន្ទាយព័ទ្ធជុំវិញប្រវែង ៥ ឬ ៦ លី។ ក្បឿងប្រក់តួប្រាសាទ កណ្ដាលធ្វើពីសំណរ ឯអគារផ្សេងទៀត សឹងប្រក់ក្បឿង ធ្វើពីដីដុតពណ៌លឿង។ សសរនិងស៊ុមទ្វារសុទ្ធតែឆ្លាក់ ឬ គូររចនារូបផ្សេងៗ តែភាគច្រើនគឺរូបព្រះពុទ្ធ។ កដំបូលទាំងនោះល្អមើលណាស់។ របៀងប្រាសាទនិងថែវយ៉ាងវែងអាចដើរបានជាផ្លូវខ្វាត់ខ្វែងហើយដំបូលនោះក៏ខ្ពស់ៗ សម្បើមណាស់។ ទីនេះជាកន្លែងព្រះរាជវាំងដែលស្ដេចទ្រង់ប្រកបកិច្ចការផែនដី មានបង្អួចមាសមួយនៅខាងស្ដាំនិងខាងឆ្វេងនៃកន្លែងស្ដេចគង់ប្រថាប់ មានសសរបួនជ្រុងតម្កល់កញ្ចក់តម្រៀបគ្នាប្រមាណជាសែសិបឬហាសិបបន្ទះ ដាក់ដង្ហែតាមជ្រុងបង្អួចនេះ កំណល់ទ្រមានរូបរាងជាដំរី[១៥]។

ខ្ញុំឮគេនិយាយថា ទីគ្រង់នេះ មានរបស់ប្លែកៗ ច្រើនណាស់ ប៉ុន្តែបំរាមតឹងតែងពេក មិនអាចអនុញ្ញាតឲ្យចូលមើល បាន។ ក្នុងបណ្ដារឿងប្លែកទាំងនោះ មានការណ៍មួយថា នៅកណ្ដាលប្រាសាទ មានប្រាង្គមាសមួយ ហើយថារាល់យប់ ស្ដេចតែងឡើងទៅផ្ទុំលើប្រាង្គមាសនោះ។ អ្នកស្រុកគេមានជំនឿហើយនាំគ្នានិយាយថា នៅក្នុងប្រាង្គមាសនោះឯង មានបិសាចមួយ មានរូបជាពស់ក្បាល ប្រាំបួន[១៦]។ បិសាច នោះជាព្រះភូមិរក្សាព្រះនគរ។ រាល់យប់ បិសាចតែងតំណែង ខ្លួនជាមនុស្សស្រី ហើយស្ដេចត្រូវរួមផ្ដេក ផ្ដិតនឹងនាង នេះសូម្បីតែមហេសី ឬ ស្នំស្និទ្ធព្រះអង្គ ក៏មិនហ៊ានចូលទៅក្នុងទីនោះដែរ។ លុះដល់មជ្ឈិមយាម ទើបស្ដេចចេញមកពីនាងពស់នោះ មករួមរ័ក្សនឹងមហេសី ឬ ស្ត្រីស្នំដទៃទៀត បាន។ បើបាត់ពស់នោះមិននិម្មិតមកទេ នោះថាគ្រោះថ្នាក់នឹងមកដល់អាយុស្ដេចហើយរឿងរ៉ាវអាក្រក់នឹងកើតឡើង។ បើស្ដេចមិនបានយាងចូលទៅទីនេះមួយយប់ណាហើយពេលនោះអព មង្គល នឹងពិតជាកើតឡើងភ្លាមមិនខានដែរ។

បន្ទាប់មក ដំណាក់ព្រះញាតិវង្សឬលំនៅនាម៉ឺន-មន្ត្រីធំៗ សង់យ៉ាងធំទូលាយស្លុកស្ដម្ភប្លែកពីផ្ទះអ្នកស្រុកសាមញ្ញ។ ផ្ទះទាំងនោះសុទ្ធតែប្រក់ស្លឹក មានតែផ្ទះអ្នកធំនិងវិហារទេ ដែលប្រក់ក្បឿង។ ហើយទំហំផ្ទះទាំងនោះត្រូវសង់ទៅតាមលំដាប់យសសក្តិនៃម្ចាស់ផ្ទះផង។

ចំណែកផ្ទះប្រជារាស្ត្រវិញ សុទ្ធតែប្រក់ស្លឹក (ឬស្បូវ) គេមិនហ៊ានប្រក់ក្បឿងទេ ឯទំហំសោត សង់ទៅតាមធនធានខ្លួន តែមិនហ៊ានសង់ធដូចលំនាំអ្នកធំឡើយ។

## ៣. សម្លៀកបំពាក់ និង គ្រឿងអលង្ការ

អ្នកស្រុកទាំងអស់ ចាប់តាំងពីស្ដេចចុះទៅ ទាំងស្រីទាំងប្រុសសុទ្ធតែបួងសក់ទាំងអស់ ហើយគេលែងខ្លួនទទេស្អាត មានតែសំពត់មួយផ្ទាំងតូចវ័ណ្ឌជុំវិញខ្លួន របៀបគេចងពុង ហើយបើត្រូវការចេញទៅណាមកណា គេយកកំណាត់មួយផ្ទាំងទៀតធំជាងមុនមករុំស្រោបថែមពីលើ។ ការស្លៀកពាក់នេះ មានល័ក្ខខ័ណ្ឌទៅតាមឋានៈទៀត។ ព្រះពស្ត្ររបស់ស្ដេច មានតម្លៃជាមាសបីឬបួនតម្លឹង គឺល្អដាច់ពីសម្លៀកបំពាក់អ្នកផងទាំងពួង។ អ្នកស្រុកនេះ ចេះត្បាញសំពត់ប្រើហើយ តែមានប្រើសំពត់មកពីស្រុកសៀម និងចាម្បផងដែរ។ សំពត់ពិសេសមកពីបស្ចិមប្រទេសដែល មានសាច់ម៉ដ្ឋល្អ មានតែស្ដេចទេដែលមានប្រើ គឺជាសំពត់ ផ្កាសរសៃសូត្រឆ្មារ។ ស្ដេចពាក់មកុដមាស បើជួនកាលមិនពាក់មកុដទេ គឺពាក់កម្រងផ្កាដូចជាផ្កាម្លិះជាដើម ព័ទ្ធជុំវិញព្រះសិរ។ នៅលើកំពូលព្រះកេស មានស្នៀតសក់ដាំត្បូងពេជ្រយ៉ាងធំទៀតផង។ គ្រាន់តែគ្រឿងអលង្ការដែលពាក់នៅនឹងព្រះបាទនិងព្រះហស្ត មានទម្ងន់ដល់ទៅជាងបីនាឡិ។ នៅគ្រប់តែម្រាមមានពាក់ចិញ្ចៀនដែលមានដាំពេជ្រភ្នែកឆ្មា។ បាតព្រះហស្តនិងបាតព្រះបាទាមានលាបពណ៌ក្រហមហើយនៅពេលដែលទ្រង់យាងចេញមកម្ដងៗ តែងកាន់ព្រះខ័នមាសមួយជានិច្ច។

ចំណែកប្រជារាស្ត្រវិញ មានតែស្ត្រីភេទទេ ដែលអាចលាបថ្នាំក្រហមនៅបាតដៃបាតជើងបាន ឯប្រុសៗមិនហ៊ានលាបទេ។ ព្រះញាតិវង្ស និងមន្ត្រីធំអាចប្រើកំណាត់ផ្ការង្វើលៗបាន ឯមន្ត្រីធម្មតា ប្រើបានតែត្រឹមផ្កាចុងជាយប៉ុណ្ណោះ ចំណែករាស្ត្រសាមញ្ញ បើស្រីៗអាចប្រើសំពត់ផ្កា បានខ្លះដែរ។

ជនជាតិចិនដែលទើបនឹងមកដល់ប្រទេសនេះថ្មីៗ ទោះបីប្រើសំពត់មានផ្កានៅជាយទាំងសងខាង ក៏គេមិនថាអីដែរ ព្រោះគេសន្មតថាជាពួកមិនទាន់ដឹងទំនៀមស្រុកហៅថា ពួកង៉ានទីង ប៉ា ឆា (មិនដឹងភាសា?)។

## ៤. អំពីមន្ត្រី

ប្រទេសនេះមានរដ្ឋមន្ត្រី មេទ័ព និងហោរា ហើយមន្ត្រីក្រោមពីនោះ មានច្រើនឋានៈទៀត ដូចជានៅប្រទេសចិនដែរ ប្លែកគ្នាតែឈ្មោះហៅ។ មន្ត្រីទាំងនេះភាគច្រើន ជាពូជពង្សរបស់ស្ដេច បើមានអ្នកក្រៅចូលធ្វើជាមន្ត្រីផង ទាល់តែអ្នកនោះយកកូនទៅថ្វាយឲ្យធ្វើជាស្នំស្ដេច។ ការធ្វើ ដំណើរនៃមន្ត្រីទាំងនោះ គេសម្គាល់តាមគ្រឿង ហែហមតាមឋានៈ។ អ្នកធំជាងគេអង្គុយលើគ្រែស្នែងមាស មានបាំងក្លស់ដងមាសបួន។ អ្នកបន្ទាប់មកទៀតគ្រែស្នែងមាសក្លស់ដងមាសពីរ ចុះមកទៀតមានគ្រែស្នែងមាសដែរ តែក្លស់ដង មាសមួយ។ អ្នកតូចមកទៀតគ្រែស្នែងប្រាក់ មានក្លស់ដង មាសមួយ។ អ្នកតូចបន្តមកចេះតែថយមកក្លស់ដងមាសតែមួយ រួចក្លស់ដងប្រាក់មួយ ឥតមានគ្រែស្នែង។

ចំពោះមន្ត្រីដែលត្រូវជិះគ្រែស្នែងប្រាក់និងក្លស់ដងមាសមួយឡើងទៅសុទ្ធតែហៅថា ប៉ាតេង(ម្រតេង)ឬ អាំតេង(អម្តែង ?)។ អ្នកដែលមានតែក្លស់ដងប្រាក់ ហៅថា **សីទ្បាត់ទី** (ស្រីស្និន?)។ ក្លស់នោះ គេយកសំពត់ជាតិសូត្រដែលធ្វើមកពីប្រទេសចិនពាស ហើយទម្លាក់ ចុងរំភាយចុះសឹងដល់ដី។ ឯឆ័ត្រតាំងយូរ គេយកសំពត់សូត្រ ពណ៌ខៀវមកពាស ហើយទំលាក់រំភាយខ្លីបន្តិចដែរ រួចយក ប្រេងមកលាបយ៉ាងរលើបទៀតផង។

## ៥. អំពី លទ្ធិសាសនាបិបែប

អ្នកចេះដឹង (ពួកព្រាហ្មណ៍?) គេហៅថា **ប៉ាន់ឃាប**[១៧] លោកសង្ឃគេហៅថា **ជូគូ** [១៨] ពួកតាបសគេហៅ **ប៉ាស៊ីវី**[១៩]។

ដែលហៅថា **ប៉ាន់ឃាប**នេះមិនដឹងជារៀនពីកន្លែងណាទេ ខ្ញុំមិនដែលឃើញសាលា ឬទីកន្លែងរៀនសោះ ខ្ញុំឃើញតែរូបពួកនេះឯងដែលស្លៀកពាក់ដូចតែជនធម្មតាដែរ ប៉ុន្តែមានប្លែកត្រង់ពាក់អំបោះសវេញមួយខ្សែនៅក ហើយអំបោះនេះ ពាក់ជាប់នឹងក អស់មួយជីវិត។ គេតែងរើសយកពួក ប៉ាន់ឃាបនេះឯង ធ្វើជាមន្ត្រី ព្រោះគេទុកជាអ្នកចេះដឹងជាន់ខ្ពស់ហើយ។

ចំណែកលោកសង្ឃវិញ កោរព្រះកេស គ្រងចីវរពណ៌លឿង បញ្ចេញស្មាខាងស្តាំ ហើយនិមន្តដោយជើងទទេ ឥតពាក់ស្បែកជើងឡើយ។ ព្រះវិហារមួយ គេអនុញ្ញាតឲ្យប្រក់ក្បឿងបាន ហើយនៅកណ្តាលព្រះវិហារនោះមានតម្កល់ព្រះ ពុទ្ធរូបមួយព្រះអង្គ ដែលមានភិនភាគ ដូចជាព្រះសក្យមុនីដែរ[២០] គេហៅថា "ពុតឡៃ" លាបលនពណ៌ក្រហម ដោយ គេយកដីសមកសូនធ្វើ ហើយលាបពណ៌ផ្សេងៗ គ្មានភិនភាគ អ្វីក្រៅពីនេះទេ។ មានព្រះពុទ្ធរូបតូចៗ ច្រើនអង្គទៀតមាន ព្រះភក្ត្រមិនដូចគ្នាទេ ច្រើនតែកសាងអំពីស្ពាន់ ហើយគ្មានជួង ស្គរ រគាំង ទង់អ្វីទាំងអស់។ ព្រះសង្ឃឆាន់ត្រីសាច់បាន តែមិនឆាន់ស្រាទេ ហើយគេអាចរៀបម្ហូបត្រីសាច់ ទាំងនេះថ្វាយព្រះផង។ ក្នុងមួយថ្ងៃលោកនិមន្តទៅបិណ្ឌបាត ពីផ្ទះបាសក តែមួយដងទេ ហើយគ្មានរៀបដណ្តាំស្លនៅក្នុងវត្តឡើយ។ លោកឆាន់មួយដងក្នុងមួយថ្ងៃ។

ធម៌ដែលលោកសូត្រមានច្រើនណាស់ គេចងក្រងនៅនឹងស្លឹកតាលព្រឹក្ស[២១] ជិតស្នាមអក្សរពណ៌ខ្មៅ តែមិនមែន សរសេរដោយជក់ ឬខ្មៅដុសឡើយ។ ខ្ញុំមិនដឹងគេសរសេរ ដោយអ្វីទេ[២២]។ គេមានយក គ្រែស្នែង និងក្លស់ដងមាស ឬដងប្រាក់ មកសែងមកបាំងលោកសង្ឃដែរ ព្រោះស្តេច តែងពិគ្រោះនឹងព្រះសង្ឃ ចំពោះបញ្ហាណាដែលធំៗ របស់ ស្រុកទេស។ ប៉ុន្តែពុំឃើញមានដូនជីនៅក្នុងវត្តទាំងនោះទេ។

រីឯពួកតាបសដែលហៅ ប៉ាស៊ីវី នេះ ស្លៀកពាក់ជាអ្នកស្រុកធម្មតាដែរ តែមានជួតក្បាលកំណាត់ពណ៌សឬពណ៌ក្រហម របៀបដូចពួកស្រីតារតា នៃជាតិម៉ុងហ្គោលដែរ តែទាបជាងបន្តិច។ ពួកនេះ មានវត្តដូចព្រះសង្ឃពុទ្ធសាសនាដែរ តែមានទំហំតូចជាង។ លទ្ធិពួកតាបសនេះ គ្មានឥទ្ធិពលខ្លាំងដូចសាសនាព្រះពុទ្ធទេ។ ពួកនេះគេគោរពថ ពោះតែថ្មមួយដុំធំ[២៣] ដូចថ្មរូបអ្នកតាព្រះស្រុក ដូច្នោះដែរ។ ប្រភពក្តី របៀបប្រតិបត្តិនៃពួកនេះក្តី ខ្ញុំពុំបានដឹងទេ។ ពួកនេះមានដូនជី ហើយវិហារក៏ត្រូវអនុញ្ញាតឲ្យប្រក់ក្បឿងបានដែរ។ ពួក ប៉ាស៊ីវី មិនបរិភោគរបស់អ្នកដទៃទេ ហើយមិនបរិភោគនៅចំពោះទីសាធារណៈផង ហើយមិនសេពសុរាជាដាច់ខាត។ ខ្ញុំមិនដែលឃើញតាបសសូត្រធម៌ឬក៏ធ្វើអំពើអ្វីជាប្រយោជន៍អ្នកផងច្បាស់នឹងភ្នែកម្តងណាឡើយ។

ចំណែកក្មេងៗកូនអ្នកស្រុកវិញ ដែលត្រូវការរៀនសូត្រគេតែង យកទៅទុកដាក់រៀនជាមួយព្រះសង្ឃហើយបួសជាសង្ឃផង លុះដល់អាយុច្រើនក៏វិលត្រឡប់មកកាន់ជីវភាពជាជនធម្មតាវិញ។ ឯការល្អិតល្អន់ជាងនេះទៅទៀត ខ្ញុំមិនបានដឹងឲ្យច្បាស់លាស់ឡើយ។

## ៦. អំពីអ្នកស្រុក

តាមទម្លាប់របស់ពួកមនុស្សដែលមិនទាន់ស៊ីវិល័យ ច្រើនតែមានរូបឆោមខ្មៅគម្រាំង មិននិយមទៅនៅលើកោះដែលសម្បូរដោយទឹកទេ ចូលចិត្តតែនៅក្នុងភូមិឆ្ងាយដាច់ស្រយាលពីគេ។ ទម្លាប់បែបនេះជាការពិតណាស់។

ចំណែកស្ត្រីក្នុងវាំងឬ ស្ត្រីក្នុងត្រកូលថ្កុំថ្កើងវិញមានសាច់សដូចចាន ព្រោះតែគេមិនងាយប្រទះនឹងកំដៅថ្ងៃឡើយ។ តាមធម្មតាទាំងស្រី ទាំងប្រុស គ្មានស្លៀកដណ្តប់អ្វីក្រៅពីសំពត់មួយផ្ទាំងរុំព័ទ្ធភ្ជាប់នឹងចង្កេះរនោះទេ។ គេលែងខ្លួនទុក ដើមទ្រូងនៅកណ្តាលវាលឯសក់បួង ជើងទទេ គ្មានស្បែកជើងឡើយ ទោះជាស្ត្រីមហេសីស្តេចក៏ដោយ។

ព្រះមហាក្សត្រមានមហេសីប្រាំអង្គ គឺអគ្គមហេសីមួយ និងមហេសីសាមញ្ញបួនប្រចាំទិសធំទាំងបួនដែរ។ ចុះពីនោះ មក ខ្ញុំឮថា មានស្រីស្នំ បួនពាន់ ឬ ប្រាំពាន់នាក់ ហើយមានចែកជាជាន់ថ្នាក់ និងមិនឲ្យចេញដើរទៅណាមកណាផ្តេសផ្តាស់ឡើយ។ ខ្ញុំចូលទៅក្នុងវាំងពេលណា ក៏ឃើញស្តេចខ្មែរចេញមកជាមួយអគ្គមហេសី ហើយគង់ប្រថាប់នៅក្នុង ស៊ុមមាស[២៤] នាល្វែងកណ្តាលធំទូលាយ។ ចំណែកមន្ត្រី អ្នកក្នុងវាំងវិញ នាំគ្នាទៅអង្គុយក្នុងថែវព័ទ្ធជុំវិញតាមលំដាប់ ថ្នាក់យសសក្តិរៀងខ្លួន ហើយនាំគ្នាលបមើលពីក្រោមស៊ុម មាសនោះមក។ ខ្ញុំបានចូលទៅឃើញម្តង គឺឲតែនរណាមានកូនក្រមុំល្អ ច្បាស់ជាត្រូវគេហៅឲ្យនាំចូលទៅក្នុងវាំង។ ពួកស្រីនៅខាងក្រោយនេះដែលដើរច្រវាត់ចេញចូលបម្រើ គេហៅថា "តាំងកេឡាង" (ស្រីង្គារ?)។ ពួកនេះមានចំនួន មិនតិចជាងមួយពាន់ ឬ ពីរពាន់នាក់ទេ តែអាចយកប្តីរស់នៅជាមួយអ្នកធម្មតាបាន។ ស្ត្រីទាំងនេះសុទ្ធតែកោរសក់ពីលើ ថ្ងាស់បន្តិច ហាក់ដូចជាពួកអ្នកបើកផ្លូវទឹកនៅស្រុកចិនខាងជើងហើយគេលាបជាតិហិង្គុលនៅត្រង់ជើងសក់ក្បែរគុម្ពត្រចៀកទាំងសងខាង។ នេះហើយជាសញ្ញាសម្គាល់ពួក តាំងកេឡាង ឬ ជេនគាឡាង គឺមានតែពួកនេះហើយដែលអាចចូលក្នុងវាំងបាន ឯអ្នកថយថោកពីនេះទៀត ចូលទៅកាន់ផ្លូវខ្វែងខ្វាត់ខាងក្រោមប្រាសាទនោះមិនបានទេ។

ស្ត្រីអ្នកភូមិធម្មតាក៏បួងសក់ដែរ ប៉ុន្តែគ្មានសៀតស្លៀតសក់និងគុបតែងលំអរលើសក់ក្បាលឬលំអរមុខឡើយ។ នៅកដៃមានពាក់កងមាសនៅនឹងម្រាមដៃ មានពាក់ចិញ្ចៀនមាស។ ម្យ៉ាងទៀតពួកជេនគាឡាងនិងអ្នកនៅក្នុងវាំង ទាំងប្រុសទាំងស្រី សុទ្ធតែលាបប្រេងក្រអូបដែលផ្សំធ្វើឡើងពីជាតិឈើក្រអូបនិងក្រលៀនប្រើស។

គ្រប់គ្រួសារទាំងអស់សុទ្ធតែគោរពប្រណិបតន៍ព្រះពុទ្ធ។

ក្នុងប្រទេសនេះ មានមនុស្សស្រីភេទខ្លះស្អាតៗ រាល់ថ្ងៃតែងដើរជាក្រុមដប់នាក់ឬលើសពីនេះ ទៅពាសពេញទីផ្សារជាញឹកញយណាស់មានបំណងទាក់ទងពួកចិន។ ដូរយករបស់មានតម្លៃដែលជាទម្លាប់មួយមិនល្អ មិនថ្លៃថ្នូរសោះ។

## ៧. អំពីស្ត្រីសម្រាលកូន

ស្រីអ្នកស្រុកនេះ ក្រោយដែលសម្រាលកូនរួចទៅ គេយកបាយក្តៅប្រឡាក់លាយអំបិល ហើយញាត់ចូលទៅក្នុងទ្វារមាស លុះដល់បានមួយយប់មួយថ្ងៃ ទើបគេយកចេញមកវិញ។ ការធ្វើដូច្នេះ ជាហេតុនាំឲ្យមិនសូវមានជម្ងឺ និងឲ្យបានរួមទ្វារមាសតូចដូចជាស្រីក្រមុំទៀតផង។ កាលខ្ញុំទើបនឹងដឹងរឿងនេះដំបូង ឆ្ងល់ថាក្រែងមិនពិតដូច្នោះទេដឹង ? ព្រោះថា បើបានជាមានប្តីនិងមានកូនទៅហើយចុះម្តេចខ្លាចគេដឹងរឿងនេះទៀត ? ប៉ុន្តែនៅនឹងផ្ទះដែលខ្ញុំសំណាក់នៅ មានស្រីម្នាក់សម្រាលកូនដែលជាហេតុនាំឲ្យខ្ញុំដឹងរឿងនេះច្បាស់លាស់ : នៅក្រោយពេលសម្រាលកូនហើយ មួយថ្ងៃទៀត ស្រីនោះពកូនខ្ចីទៅមុជទឹកទន្លេ ដែលជាការចំឡែកមិនដែលជួបប្រទះទេ។

នៅពេលដែលខ្ញុំទៅជួបនឹងគេម្តងណា គេតែងពោលថា ស្រីស្រុកនេះក្រាស់ដោយកាមតណ្ហាណាស់។ ក្រោយពេលដែលសម្រាលកូនហើយមួយថ្ងៃ ឬ ពីរថ្ងៃប៉ុណ្ណោះ គេក៏ រួមដំណេកជាមួយប្តីទៀតហើយ។ បើប្តីនោះបំពេញចំណង់ខ្លួនមិនបានទេ នឹងត្រូវគេបោះបង់ចោលដូចពួកបូយឆេង[២៥] មិនទាន។ ប្រសិនប្តីនោះមានធុរៈទៅស្រុកឆ្ងាយអស់ពេលច្រើនយប់ ចាប់ពីដប់យប់ឡើងទៅ ច្បាស់ជាត្រូវប្រពន្ធស្តីឲ្យថា "ខ្ញុំមិនមែនស្រីខ្មោចទេ តើឲ្យខ្ញុំដេកម្នាក់ឯងម្តេចនឹងបាន?"។ ខ្ញុំឮថាមានស្រ្តីច្រើនណាស់រក្សាទុកសេចក្តីបរិសុទ្ធរបស់ខ្លួន។ ស្រីៗច្រើនតែឆាប់ចាស់ណាស់ ពីព្រោះ តែគេឆាប់មានប្តី ឆាប់មានកូនពេក។ មនុស្សដែលមានអាយុ ២០ ឬ ៣០ គឺប្រហែលគ្នានឹងជនជាតិចិនដែលមានអាយុ ៤០ ឬ ៥០ ឆ្នាំដូច្នោះដែរ។

## ៨. អំពីស្រ្តីក្រមុំ

ពួកឪពុកម្តាយដែលមានកូនស្រី តែងឲពរកូនថា "សូមឲ្យឯងទៅអនាគតបានជាស្រីដែលមានប្តីរាប់រយពាន់ "[២៦]។

កូនស្រីក្នុងគ្រួសារអ្នកមាន ចាប់ពីអាយុ ៧ ទៅ ៩ ឆ្នាំ គ្រួសារអ្នកក្រខ្សត់រហូតដល់អាយុ១១ ឆ្នាំ គេនិមន្តលោកឬតាបសមកបើកមុខកូនស្រីហៅថា ឆឹនថាន់[២៧]។

ពិធីនេះ រាជការដាក់កម្រិតឲ្យធ្វើមួយឆ្នាំម្តង នៅក្នុងខែដែលត្រូវនឹងខែទី ៤ របស់ចិន ដោយរើសយកថ្ងៃណាមួយធ្វើតែម្តង។ អ្នកមានកូនស្រីដែលត្រូវធ្វើពិធីនេះ តោងជម្រាបរាជការជាមុន ហើយអ្នករាជការ គេក៏ឲ្យទៀនធំមួយដើម មកទុកមុន និងមានគូសគំនូសមួយជាកំណត់សញ្ញាផងថាដល់ពេលយប់ធ្វើពិធីនេះ បើដុតទៀនអស់ត្រឹមគន្លាក់នោះហើយ ត្រូវចាប់ពិធី ឆឹនថាន់ឡើង។

នៅមុនពេលដែលធ្វើពិធីនេះមួយខែឬកន្លះខែឬដប់ថ្ងៃ ឪពុកម្តាយត្រូវជ្រើសរើសលោកឬតាបសណាមួយប្រកាន់ទុកជាមុន ទោះបីនៅវត្តណាក៏ដោយ ក៏តែងតែមានគេទៅនិមន្តដែរ។

លោកគ្រូអង្គណាដែលសំខាន់ៗជាងគេតែងតែត្រូវពួកមន្ត្រីឬអ្នកមានគេនិមន្តទុកអស់ហើយ ឯអ្នកក្រពុំអាចជ្រើសរើសរកលោកបានតាមចំណង់ឡើយ។ មន្ត្រីឬអ្នកមាន គេបូជាលោកនូវសុរា អង្ករ កំណាត់សំពត់ ស្លាម្លូ និងគ្រឿងប្រាក់យ៉ាងច្រើនរហូតដល់ទៅ ១០០ អម្រែកផងហើយមានតម្លៃប្រមាណមិនតិចជាងសាច់ប្រាក់ចិន ២០០ឬ៣០០ តម្លឹងឡើយ។ អ្នកមានរបស់របរតិចក៏គង់៣០-៤០ឬ១០-២០ អម្រែកដែរ។ ដូច្នេះ គ្រួសារអ្នកក្រត្រូវរង់ចាំដល់កូនស្រីអាយុ ១១ ឆ្នាំទើបចាប់ធ្វើពិធីនេះមកពីពិបាករករបស់របរទាំងនេះឯង។

មានអ្នកខ្លះ គេជួយលុយដល់កូនអ្នកក្រឲធ្វើពិធីនេះដែលគេទុកជាការសាងកុសលមួយដែរ។ ក្នុងមួយឆ្នាំ លោកឬតាបសមួយអង្គ អាចទទួលនិមន្តធ្វើពិធីនេះឲ្យក្មេងស្រីបានតែមួយនាក់ទេ បើលោកយល់ព្រមនឹងអ្នកណាមួយហើយមិនអាចទទួលអ្នកដទៃទៀតបានទេ។

នៅពេលយប់ដែលធ្វើពិធីនេះ គេមានរៀបចំគ្រឿងស៊ីផឹកនិងភ្លេងភ្លាត់ទ្រហឹងអឺងកង។ ក្រៅពីការជួបជុំញាតិមិត្តជិតឆ្ងាយ គេមានសង់ធ្វើជារោងមួយ តម្កល់រូបមនុស្ស រូបសត្វដែលសូនធ្វើអំពីដី។ អ្នកមានយសសក្តិធ្វើរូបនេះដល់ទៅជាងដប់ ឯអ្នកហោចមកក៏មានបីឬបួនដែរ។

ចំពោះអ្នកដែលទាល់ក្រខ្លាំងវិញ គ្មានធ្វើរូបនេះទេ គិតតែរៀបពិធីតែម្តងទៅ លុះដល់គ្រប់ពេលប្រាំពីរថ្ងៃ ទើបគេរុះរោងនោះចេញ។ នៅយប់ដែលធ្វើពិធីនោះទៀត គេយកគ្រែស្នែងទៅនិមន្តលោក ហើយបាំងក្លស់និងលេងភ្លេងដង្ហែនាំយកមក។ គេមានកូនតូបពីរដូចគ្រែស្នែងដែរ ដែលបិទបាំងលំអរដោយព្រៃពណ៌ភ្លឺព្រាល។ តូបមួយសម្រាប់ឲ្យកូនស្រីនោះអង្គុយ ឯតូបមួយទៀតសម្រាប់លោកឬតាបសគង់សូត្រធម៌ តែខ្ញុំមិនដឹងជាលោកសូត្រអ្វីឡើយ។ ពេលនោះភ្លេងក៏ប្រគុំឮគឹកកងរំពងដែរ។ ខ្ញុំឮថាយប់នេះគ្មានត្រណមអ្វីទេ គ្រាន់តែដឹងថាដល់ពេលវេលាភ្លាម លោកឬតាបសនោះក៏ចូលទៅក្នុងបន្ទប់ជាមួយកូនស្រី ហើយលូកដៃរបស់លោកផ្ទាល់ទៅយករបស់កូនស្រី ដាក់ទៅក្នុងស្រា[២៨]។ ខ្លះថាឪពុកម្តាយនិងញាតិមិត្ត យកទៅផ្តិតនឹងថ្ងាស់ឬមុខ រៀងខ្លួន។ ខ្លះទៀតថាយកមកភ្លក្សគ្រប់គ្នា ហើយខ្លះថាលោកក៏រួមរ័ក្សជាមួយកូនស្រីក្នុងពេលនោះ តែខ្លះថាឥតមានទេ។ រឿងនេះ គេមិនឲ្យពួកចិនបានឃើញផ្ទាល់ទេ ហេតុនេះទើបខ្ញុំមិនអាចបានដឹងនូវការពិតឡើយ។

លុះដល់ពេលទៀបភ្លឺទើបគេដង្ហែលោកដោយគ្រែស្នែងមានភ្លេងនិងបាំងក្លស់នាំយកទៅវិញ ហើយគេយករបស់ល្អៗ មានព្រៃពណ៌ជាដើម ទៅធ្វើជាថ្នូរលស់យកកូនស្រីនោះមកវិញ។ បើពុំធ្វើដូច្នេះទេ កូនស្រីនេះមិនអាចយកទៅឲ្យមានប្តីដទៃទៀតបានឡើយ ព្រោះនៅជាកម្មសិទ្ធិរបស់លោកនៅឡើយ។

ពេលដែលខ្ញុំបានឃើញរឿងរ៉ាវនេះ គឺនៅថ្ងៃ៦ ខែទី៤ នៃឆ្នាំ តេងអ៊ីវក្នុងរជ្ជកាលស្តេច តាយតេក (គ.ស. ១២៩៧)។

នៅពេលដែលមុនធ្វើពិធីនេះ កូនស្រីត្រូវនៅដេកក្នុងបន្ទប់ជាមួយឪពុកម្តាយ លុះដល់ធ្វើពិធីនេះរួចហើយ កូនស្រីត្រូវបែកទៅដេកបន្ទប់ដទៃ ហើយនាងចង់ទៅដេកកន្លែងណាក៏បាន តាមចិត្តចង់ឥតមាននរណាតាមមើលគយឃ្លាំឡើយ។

ចំពោះរឿងរៀបអាពាហ៍ពិពាហ៍វិញ ពិតមែនតែមានតម្រូវឲ្យជូនលុយកាក់ជាច្រើន ប៉ុន្តែគេមានអនុគ្រោះច្រើនដែរ។ មានខ្លះគេអាចដេកនៅរួមរ័ក្សនឹងគ្នាជាមុនទៅហើយទើបរៀបការជាក្រោយក៏បាន។ តាមប្រពៃណីគេមិនមានចាត់ទុកការណ៍នេះជាការគួរខ្មាសអៀនឬជាចម្លែកឡើយ។

នៅយប់ដែលធ្វើពិធី "ឆឹនថាន់" នោះជួនកាលនៅតែតាមផ្លូវមួយមានដល់ទៅដប់ផ្ទះឯនោះរៀបធ្វើពិធីនេះ។ នៅតាមទីក្រុងអ្នកណាហ៊ានដើរកាត់ហ្វូងពិធីពីមុខលោកឬតាបសទាំងនេះ ច្បាស់ជាវង្វេងវង្វាន់ផ្លូវហើយ ណាមួយឮគឹកកងស័ព្ទសូរភ្លេងគ្មានចន្លោះត្រង់ណាទេ។

## ៩. អំពីទាសាទាសី

គេសុទ្ធតែទិញមនុស្សព្រៃ[២៩] យកមកបង្ខំឲ្យធ្វើជាទាសាទាសី។ អ្នកដែលមានច្រើន គឺទាសាដល់ទៅជាងមួយរយនាក់ ឯអ្នកដែលមានតិចក៏ត្រឹមដប់ ម្ភៃនាក់ដែរ លើកលែងតែអ្នកក្របំផុតទើបគ្មានសោះ។

ចំណែកមនុស្សព្រៃទាំងនោះគឺជាអ្នករស់នៅក្នុងព្រៃភ្នំ មានជាវង្សត្រកូលមួយហៅថាអាចោរ "ចុង" [៣០] (ជង?)។ ពួកនេះបើមកនៅកន្លែងណាហើយ មិនហ៊ានចេញដើរទៅណាក្រៅផ្ទះឡើយ។ ពួកអ្នកស្រុកក្រុងគេឈ្លោះគ្នា គេជេរគ្នាថា "អាចុងៗ" ដូច្នេះ គេខឹងខ្លាំងណាស់ ព្រោះទុកជាការមើលងាយយ៉ាងធ្ងន់។ ក្មេងៗ មានកម្លាំងពេញ គេលក់បានតម្លៃមួយរយ "ប៉ូវ" [៣១] បើចាស់ៗ ខ្សោយកម្លាំងបានតែសាមសិបឬសែសិបទេ។

ពួកនេះ គេឲ្យនៅតែក្រោមផ្ទះ លុះត្រាមានការប្រើចាំបាច់ទើបគេអនុញ្ញាតឲ្យឡើងលើផ្ទះ ហើយត្រូវឲ្យលុតជង្គង់ លើកដៃសំពះគេសិន ទើបអាចដើរចូលក្នុងផ្ទះបាន។ គេហៅម្ចាស់គេថា ប៉ាថូ [៣២] ហៅម្ចាស់ស្រីថា មី [៣៣]។ ប្រសិនបើមានកំហុសត្រូវគេវាយដំវិញ ពួកនេះសុខចិត្តជ្រប់មុខ បណ្ដោយឲ្យគេវាយតាមចិត្ត មិនហ៊ានរើបម្រះឡើយ។ ពួកនេះស្រី-ប្រុស គេយកតែគ្នាគេជាប្ដី-ប្រពន្ធ គ្មានសិទ្ធិយកអ្នកដទៃឡើយ។ បើមានពួកចិនទៅនៅស្រុកនោះយូរ លួចរួមរ័ក្សជាមួយស្ត្រីពួកនោះ ដោយការស្រេកឃ្លានកាមតណ្ហា ហើយម្ចាស់គេទាន់ នោះអ្នកផងគេលែងឲ្យចិននេះឯងអង្គុយជាមួយគេហើយ ព្រោះខ្លួនលួចលាក់ជាមួយពួកទាសៈ។ បើពួកទាសៈទាំងនេះទាក់ទងលួចលាក់ជាមួយអ្នកក្រៅ រហូតដល់មានផ្ទៃពោះ កើតបានជាកូនទៅ ក៏ចៅហ្វាយនាយឥតសួររកហេតុផលឡើយ។ បានជាគេមិនសួរមកពីគេយល់ថាបើទាសៈនោះ កាលណាបានកូនមក នឹងបានផលដល់គេ ព្រោះថ្ងៃក្រោយគេនឹងចម្រើនទាសៈឡើងទៀត។

បើទាសៈណាលួចរត់ ហើយគេតាមចាប់បានមកវិញ គេត្រូវយកមកសាក់មុខចំកណ្ដាលថ្ងាស់ពណ៌ខៀវ ជាគ្រឿងចំណាំ ហើយគេដាក់ឃ្នាងជាប់នឹងក ជួនដាក់ឃ្នាងជាប់ទាំងដៃជើងទៀតផង។

**១០. អំពីភាសា**

ភាសាចិនបានសម្លេងប្រហាក់ប្រហែលនឹងភាសាអ្នកស្រុកនេះដែរ តែនិយាយប្រស្រ័យស្ដាប់គ្នាមិនបានទេ ស្រុកនេះមានភាសាមួយពិសេស ទោះបីជាភាសាអ្នកជិតខាងខ្លួនដូចជាចាម្បឬសៀមក៏មិនអាចដូចគ្នាស្ដាប់គ្នាបានឡើយ។ ១ គេថាបួយ ២ ថាព័ក ៣ ថាបេក ៤ ថាពួន ៥ ថាពុណាំ ៦ ថាពុណាំបួយ ៧ ថា ពុណាំព័ក ៨ ថាពុណាំបេក ៩ ថាពុណាំពួន ១០ ថាតាប់។ គេហៅឪពុកថា "ប៉ាថូ" ឪពុកធំ ឪពុកមាក៏ហៅ ប៉ាថូ ដែរ។ ម្ដាយ គេហៅ មី ឯម្ដាយមីង និងស្ត្រីអ្នកជិតខាងក៏គេហៅមីដែរ។ បងស្រីប្រុសហៅថា ប៉ង ប្អូនប្រុសស្រីហៅថា "ផូវអ៊ុង"។ មាខាងម្ដាយហៅថា "ងាកឡៃ" ឯប្ដីរបស់ម្ដាយមីងខាងឪពុកហៅថា "ពូឡៃ"។ គេប្រើពាក្យយកខាងចុងជាដើមបញ្ច្រាស់គ្នា។ ឧបមាដូចពាក្យ "នេះមនុស្សទាសាំ ជាប្អូន" គេថា "ផូងអ៊ុងទាសាំ" ពាក្យថា "នេះមនុស្សលីស៊ីមាខាងឪពុក" គេថា"ងាន ឡៃ លីស៊ី"ឧបមាមួយទៀតដូចពាក្យគេហៅចិនថា "ពីស៊ី" ហៅមន្ត្រីថា "ប៉ាតេង" ហៅអ្នកប្រាជ្ញថា "ប៉ានឃាប" លុះដល់គេចង់ថាមន្ត្រីចិនឬអ្នកប្រាជ្ញចិន គេមិនថា **ពីស៊ីប៉ាតេង** ឬ **ពីស៊ីបានឃាប**ទេ គេទៅជាប្រើថា **ប៉ាតេងពីស៊ី** ឬ **ប៉ានឃាបពីស៊ី**[៣៤] ទៅវិញ។

ទាំងនេះ គ្រាន់តែលើកយកជាឧទាហរណ៍គោលៗទេ។ មួយយ៉ាងទៀត គឺមន្ត្រីគេនិយាយតាមបែបមន្ត្រី អ្នកប្រាជ្ញនិយាយគ្នាតាមភាសាអ្នកប្រាជ្ញ លោកសង្ឃឬតាបសក៏មានពាក្យសម្ដីប្រើរបៀបខ្លួនជាសង្ឃ ជាតាបស ឯអ្នកស្រែចម្ការក៏និយាយប្លែកតាមបែបរបស់គេដែរ មិនប្លែកអ្វីពីរបៀបប្រើភាសាអ្នកស្រុកចិនទេ។

**១១. អំពីមនុស្សព្រៃ**

មនុស្សព្រៃមានពីរបែប។ មួយពួកជាពួកចេះនិយាយភាសាអ្នកស្រុកស្ដាប់គ្នាបាន គឺពួកមនុស្សព្រៃលក់ខ្លួនជាទាសៈបម្រើគេនេះឯង។ មួយពួកទៀត គឺពួកមនុស្សព្រៃដែលនិយាយស្ដាប់ភាសាគ្នាមិនបាន គ្មានរស់នឹងការចម្រើន។ ពួកនេះ គ្មានចេះធ្វើផ្ទះជ្រកនៅទេ តែងនាំគ្នាទាំងគ្រួៗដើររស់នៅតាមភ្នំ។ ក្បាលគេមានពាក់អ្វីម៉្យាងធ្វើពីដី រាងដូចឆ្នាំង។ បើដើរទៅជួបនឹងសត្វព្រៃ គេបាញ់នឹងព្រួញឬពួយនឹងលំពែង បានសត្វនោះមកក៏គូសដុំថ្មយកភ្លើងចំអិនសត្វ រួចអង្គុយដំកង់ចែកគ្នាស៊ី។ រួចហើយដើរទៅទៀត។ ពួកនេះកាចសាហាវណាស់ តែងសម្លាប់គ្នានៅក្រុមជាមួយ ហើយចេះផ្សំថ្នាំពិសពូកែសក្ដិសិទ្ធណាស់។ នៅដីវាលជិតខាងកន្លែងនៅ គេមានដាំសណ្ដែកគួ ដើមក្រវាញនិងដាំកប្បាសត្បាញសំពត់ជាវិជ្ជាជីវៈ។ សំពត់របស់គេនោះ សាច់ក្រាស់គ្រើម ហើយមានពណ៌ក្រវេមក្រវាមណាស់ផង។

**១២. អំពីអក្សរសាស្ត្រ** [៣៥]

លិខិតធម្មតានិងអត្ថបទទាំងអស់ ដូចជាឯកសារផ្លូវការជាដើមសុទ្ធតែសរសេរលើស្បែកសត្វប្រើស រមាំង ឬស្បែកដទៃទៀតដែលគេយកមកហាលស្ងួតលាបពណ៌ខ្មៅ។ គេកាត់ស្បែកនោះឲ្យមានទំហំធំឬតូចទៅតាមសេចក្ដីត្រូវការ និងយកម្សៅម៉្យាងមកប្រើមានសណ្ឋានដូចដីសនៅស្រុកចិន ដោយលញ់ឲ្យវែង ចិតចុងស្រួច គេហៅថា សោ[៣៦] ហើយគេសរសេរដោយដៃ បានជាប់ជិតល្អណាស់មិនងាយនឹងរលុបឡើយ។ កាលណាគេសរសេរហើយ គេយកដីសនោះមកសៀតនឹងត្រចៀក នាំឲ្យគេចំណាំបានថាអ្នកនេះហើយជាអ្នកសរសេរ។ បើសរសេរហើយត្រូវការលុបវិញ គោងប្រើរបស់ទទឹកយកមកជូតទើបរលុបអក្សរនោះទៅវិញ។ អក្សរនេះមានសណ្ឋានដូចអក្សរជនជាតិហួយតូវ (តួរក៏) ដូច្នោះដែរ។ការសរសេរជាលិខិតអ្វីក៏ដោយ គេសុទ្ធតែសរសេរពីក្រោយទៅមុខមិនមែនសរសេរពីលើចុះក្រោមទេ។ ខ្ញុំឮអ៊ាសាយហាយ៉ានិយាយថាស្រៈនៃអក្សររបស់គេស្រដៀងគ្នានឹងអក្សរជាតិម៉ុងហ្គោលដែរ មានប្លែកគ្នាតែពីរបីប៉ុណ្ណោះ។ កាលនោះគ្មានអត្ថបទបោះពុម្ពទេ ប៉ុន្តែមានអ្នកនិពន្ធនិងអ្នកតែងពាក្យពេចន៍ដែរ។

**១៣. អំពីពេលចូលឆ្នាំ**

គេយកខែទី ១០ របស់ចិនធ្វើជាខែទី ១ ហើយខែនោះមានឈ្មោះថា**កាតិក** (កក្ដិក ?) [៣៧]។ នៅពីមុខវាំង គេមានសង់វេទិកាមួយយ៉ាងធំ ដែលអាចដាក់បានមនុស្សជាងមួយពាន់នាក់ ហើយគេចងប្រទីបផ្កាលានិងផ្កាភ្លើជាដើម លំអនៅលើថ្នាក់នោះ។ នៅពីមុខដែលឃ្លាតពីទីនេះប្រមាណជា ២០០ ហត្ថ មានទីលានមួយទៀត គេបន្តឈើធ្វើជារោងរន្ទាដែលមានកំពស់ដល់ទៅជាង ២០០ ហត្ថ។ ក្នុងយប់នោះ គេមានអុជកាំជ្រួច រន្ទា ឬ ផាវ បី-បួន ឬ ប្រាំកន្លែង។ នៅក្នុងរោងនោះ មានសុទ្ធតែមន្ត្រីធំ-តូច គ្រប់ជាន់ថ្នាក់។ វេលានោះស្ដេចក៏យាងចេញមកទតកាំជ្រួច រន្ទា និង ផាវ ដែលគេអុជនៅខាងក្រៅ ចម្ងាយ ១០០ លីតែគេអាចមើលឃើញ និងស្ដាប់ឮសូរយ៉ាងច្បាស់ ឮខ្លាំងមើលតែកាំភ្លើងធំទ្រហឹងខ្ទរខ្ទារពេញតែទីក្រុង។

មន្ត្រីនិងញាតិវង្សទាំងអស់ចែកគ្នាកាន់ទៀននិងម្លូស្លា ដែលជាហេតុនាំឲ្យចំណាយអស់ប្រាក់យ៉ាងច្រើន។ នៅក្នុងពិធីនេះ ស្ដេចបានអញ្ជើញពួកទូតបរទេសទៅចូលរួមផងដែរ។ គេធ្វើដូចនេះ អស់រយៈកន្លះខែបានចប់។
នៅក្នុងខែនីមួយ ៗ សុទ្ធតែមានពិធីបុណ្យដែរ ដូចជានៅខែទី ៤ គេបោះឈូង ខែទី ៩ ធ្វើអ៊ាបឡាក់[៣៨] ពិធីនេះគេហៅប្រជុំមនុស្សមកចូលក្នុងទីក្រុង ហើយហាត់ក្បួនដើរដង្ហែកាត់មុខវាំង។ ខែទី ៥ គេទទួលយកទឹកមន្តព្រះពុទ្ធ ពីគ្រប់ទីជិតឆ្ងាយពេញទាំងអាណាចក្រយកមកស្រោចស្រង់ថ្វាយព្រះរាជជម្រះកាយ ហើយអុំនាវានៅលើគោក (អុំទូកគោក) ឯស្ដេចយាងឡើងលើកើយប្រាសាទទតមកពិធីនេះ។ ខែទី ៧ ធ្វើពិធីដុតភ្នំស្រូវ។ ពេលនោះស្រូវទើបនឹងទុំថ្មី គេទទួលយកមកតាមទ្វារខាងត្បូង ហើយគេគរដុតថាជាការបូជាចំពោះព្រះពុទ្ធ។ មានស្រីៗជាច្រើនណាស់ជិះរទេះឬជិះដំរី នាំគ្នាមកមើលពិធីនេះ ឯព្រះរាជាមិនចេញមកក្រសាលទតពិធីនេះទេ

ទ្រង់គង់នៅឯព្រះដំណាក់។ ខែទី៨ ធ្វើពិធីអែឡាំ[៣៩] ពិធីនេះគឺគេរាំរែក។ គេចាត់អ្នករាំនិងអ្នកភ្លេងពូកែៗ ឲ្យចូលទៅរាំអែឡាំឯក្នុងវាំងរាល់ៗថ្ងៃ។ ក្រៅពីនេះ មានប្រជល់ជ្រូកនិងប្រជល់ដំរីទៀត។ ពិធីនេះ ស្តេចក៏អញ្ជើញពួកទូតប្រទេសក្រៅចូលទស្សនាផងដែរ។ គេធ្វើដូច្នេះរហូតដល់គ្រប់ដប់ថ្ងៃ។ ឯខែដ៏ទៃទៀត ខ្ញុំមិនបានកត់ត្រាឲ្យច្បាស់លាស់ទេ។ អ្នកស្រុកនេះក៏មានអ្នកចេះវិជ្ជាតារាសាស្ត្រដូចចិនដែរ អាចនឹងដេញរកថ្ងៃខែណាធំតូចឬសូរ្យគ្រាស ចន្ទគ្រាសដែរ តែថ្ងៃ-ខែធំតូចនេះ មិនដូចគ្នានឹងប្រទេសចិនទេ។ បើឆ្នាំណាជាឆ្នាំអធិកមាស គេក៏មានលើកខែដែរ។ ខែដែលត្រូវលើកនោះ គឺខែទី៩[៤០] ប៉ុន្តែខ្ញុំមិនបានដឹងការនេះសព្វគ្រប់ទេ។ ក្នុងមួយយប់ គេចែកចេញជាប្រាំយាម។ ប្រាំពីរថ្ងៃរាប់ជាមួយជុំ គឺដូចគ្នានៅស្រុកចិន ហៅថា កាយ-ពី-ភៀន-ជូ។

អ្នកស្រុកនេះ គ្មានប្រើនាមត្រកូល (សែ) គ្មានឈ្មោះ ហើយមិនចេះកត់ថ្ងៃខែកំណើតផង ភាគច្រើនគេយកឈ្មោះថ្ងៃដែលកើតហៅជាឈ្មោះមនុស្ស។ តាមក្បួនយាមថា ក្នុងមួយសប្តាហ៍មានពីរថ្ងៃល្អបំផុត បីថ្ងៃល្អមធ្យម ពីរថ្ងៃអាក្រក់ ហើយថ្ងៃណាត្រូវចេញដំណើរបែរមុខទៅទិសបូព៌ា ឬត្រូវឆ្ពោះទៅទិសបស្ចិម។ ពួកស្រីៗក៏ចេះរាប់ថ្ងៃខែដែរ។ ឆ្នាំទាំង ១២ មានយកសត្វជាដំណាងដូចឆ្នាំរបស់ចិនដែរ តែគេហៅឈ្មោះខុសគ្នា ឧបមាដូចគេហៅឆ្នាំសេះថា **ប៉ុកសាយ** ឆ្នាំមាន់ហៅថា **ឡាក់** ឆ្នាំជ្រូកហៅថា **ចេកលូ** និងឆ្នាំគោហៅ **គូ** ជាដើម។

## ១៤. អំពីការកាត់ក្តី

រឿងប្រជារាស្ត្រក្តីក្តាំគ្នា ពិតមែនតែជាការតូចតាចប៉ុន្តែ ជាការមួយគួរឲ្យចង់ដឹងចង់ឮដែរ។

រឿងក្តីក្តាំរបស់រាស្ត្រ សុទ្ធតែឡើងគាល់រហូតដល់ស្តេចឱ្យជម្រះក្តី។ ដើមឡើយស្តេចឥតមានវាយតប់ដោយរំពាត់ធំឬតូចឡើយ មានតែពិន័យជាមាសប៉ុណ្ណោះ។ បើអ្នកនោះមានះមិនព្រមធ្វើតាម ឬមានទោសធ្ងន់នោះ គេមិនចាប់ចងយកទៅប្រហារជីវិតដែរ គ្រាន់តែនាំចេញទៅទ្វារខាងលិច ហើយឱ្យជីករណ្តៅកប់អ្នកទោសនោះនិងយកដីឬថ្មកប់គ្របពីលើប៉ុណ្ណោះ។

ទោសស្រាលបន្ទាប់មក គឺកាត់ម្រាមដៃជើង មានខ្លះ ត្រូវគេកាត់ច្រមុះចោលក៏មានដែរ។ រឿងសហាយស្មន់និងលេងល្បែង ឥតមានហាមឃាត់ទេ។ បើប្តីរបស់ស្រីដែលមានសហាយនោះដឹង គេយកឈើពីរទៅចងគាបជើងរបស់ប្រុសសាហាយនោះឲ្យឈឺស្ទើរនឹងស្លាប់។ បក្សពួកខាងប្រុសទាំងប៉ុន្មានត្រូវរួចខ្លួន។ ឯអ្នកដែលផ្តើមគំនិតបោកប្រាស់គេត្រូវមានទោសដែរ។ បើមានមនុស្សស្លាប់នៅនឹងទ្វារកំពែង គេយកខ្សែចងអូសទៅទីវាលក្រៅទីក្រុង ហើយសម័យនោះគ្មានការពិនិត្យសាកសពអ្វីទេ។ បើគេចាប់បានចោរ ក៏អាចនាំទៅឃុំឃាំងសួរចម្លើយដែរ តែមានការគួរឲ្យអស់សំណើច គឺថាបើគេសង្ស័យថាជននោះជាចោរ ហើយជននោះមិនព្រមទទួលសារភាព គេនឹងយកខ្ទះមកដាំខ្លាញ់ឲ្យក្តៅមែនទែន ហើយគេឲ្យជននោះលូកដៃទៅក្នុងខ្លាញ់កំពុងពុះនោះឯង។ បើជននោះជាចោរមែនក៏ត្រូវរលាករលួយដៃ បើមិនមែនជាចោរទេឥតមានរលាកឡើយ។ គេប្រាប់ខ្ញុំថា អ្នកស្រុកនេះចេះមន្តអាគមពូកែណាស់។ ម្យ៉ាងទៀត បើមានគ្រួសារពីរក្តីក្តាំគ្នា ហើយរកកាត់សេចក្តីថានរណាត្រង់រៀចមិនកើត គេធ្វើដូច្នេះ នៅពីមុខវាំងមានប្រាសាទថ្មតូចៗ ១២ ខ្នង ហើយគេបញ្ជាកូនក្តីឲ្យចូលទៅអង្គុយក្នុងប្រាសាទនោះមួយម្នាក់។ គេឲ្យអង្គុយតាំងពីមួយ ថ្ងៃ ពីរ បី ឬបួនថ្ងៃទៅ បើនរណាដែលជាអ្នកធ្វើខុសនឹងច្បាប់នោះ ពិតជាមានភស្តុតាងលេចឡើងមិនខាន គឺបើមិនចេញកមរមាស់ទេ ក៏ក្អកក្តៅផ្តាសាយដែរ។ ឯអ្នកទៀងត្រង់ឥតមានផលរមាស់អ្វីឡើយ។ ការវិនិច្ឆ័យដូច្នេះ គេហៅថា **គុក សួគ៌**[៤១]។ រឿងធ្វើដូច្នេះបានមកពីព្រះភូមិរក្សាទឹកដីរបស់គេពូកែសក្តិសិទ្ធិណាស់ ទើបគេអាចធ្វើដូច្នេះទៅកើត។

## ១៥. អំពីជម្ងឺស្រែង [៤២]

អ្នកស្រុកមានកើតជម្ងឺស្រែងច្រើនគ្នាណាស់ មកពីគេចូលចិត្តមុជត្រាំក្នុងទឹក ហើយឧស្សាហ៍កក់លាងសក់ក្បាល តែងមានកើតជម្ងឺស្រែងច្រើនណាស់។ នៅតាមផ្លូវថ្នល់ ពួកនេះមិនសូវអៀនខ្មាសទេ។

ខ្ញុំឮគេថា ពួកទាំងនេះតែគេរួមរ័ក្សគ្នាភ្លាម គេចុះទៅងូតទឹកហើយ ដូច្នេះតែងមានជម្ងឺមួល បណ្តាលឲ្យស្លាប់អស់ ៨-៩ នាក់ដែរ ក្នុងបណ្តាមួយពាន់នាក់។ នៅទីផ្សារមានលក់ថ្នាំសម្រាប់កែរោគដែរ តែមិនដូចថ្នាំចិនទេ មិនដឹងជាថ្នាំអ្វីឡើយ ថែមទាំងមានគ្រូមន្តអាគមដើរព្យាបាលរោគឱ្យគេជាការគួរអស់សំណើចណាស់។

## ១៦. អំពីមរណភាព

មនុស្សស្លាប់ គេឥតមានដាក់ក្តារមឈូសទេ គេយកតែកន្ទេលក្រាលពីក្រោម យកកំណាត់សំពត់គ្របពីលើ ហើយគេយកទៅព្រៃហើយ។ កាលពីដើម គេក៏ប្រើទង់ព្រលឹងនិងភ្លេងភ្លាត់ហែខ្មោចដែរ ហើយគេលីងលាចពីរមុខបាចតាមផ្លូវនាំមុខខ្មោច លុះសែងទៅដល់ក្រៅក្រុងដល់កន្លែងណាស្ងាត់ គេក៏ដាក់ចោលខ្មោចនោះហើយត្រឡប់មកវិញ។ បើមានសត្វខ្លែងឬតិរច្ឆានអ្វីដទៃទៀតស៊ីខ្មោចនោះអស់មួយរំពេចទៅ គេថាឪពុកម្តាយនោះមានភ័ព្វបានសុខសប្បាយល្អណាស់ តែបើគ្មានសត្វស៊ីសោះឬមានស៊ីដែរតែមិនអស់វិញ គេបែរជាយល់ថាឪពុកម្តាយនេះមានពៀរមានទោសទើបបានជាដូច្នេះ។

លុះមកដល់គ្រាឥឡូវនេះ មានគេយកខ្មោចនៅទៅដុតបូជាខ្លះៗហើយ។ ពួកអ្នកដែលមានជាប់ពូជជាកូនចៅចិន ឪពុក ម្តាយស្លាប់ទៅគេឥតស្លៀកពាក់សកាន់ទុក្ខទេ។ ប្រុសគ្រាន់តែកោរសក់ ស្រីគេគ្រាន់តែកាត់សក់ខាងមុខធ្លាក់មកលើថ្ងាស់ប៉ុនមួយទះ ក៏ចាត់ជាការកាន់ទុក្ខហើយ។

ចំណែកស្តេចវិញ មានប្រាសាទសម្រាប់កប់ ប៉ុន្តែមិនដឹងជាកប់ខ្លួនទាំងមូលឬកប់តែឆ្អឹងទេ។

## ១៧. អំពីការភ្ជួរដាំ

ប្រហែលជាក្នុងមួយឆ្នាំ គេអាចសាបព្រោះនិងច្រូតស្រូវបានបីឬបួនលើក ពីព្រោះរដូវទាំងបួនមានធាតុអាកាសស្រួលល្អ ដូចជានៅខែទី ៥ ទី ៦ ដែរ។ ម្យ៉ាងទៀតស្រុកនេះគេមិនស្គាល់ដូចម្តេចថាធ្លាក់ព្រិលឬទឹកកកឡើយ។ ស្រុកគេកន្លះឆ្នាំមានភ្លៀង កន្លះឆ្នាំឥតមានភ្លៀងសោះ។ ចាប់តាំងពីខែទី ៤ ដល់ខែទី ៩ តែដល់ពេលរសៀលមានភ្លៀងធ្លាក់រាល់ថ្ងៃ ទឹកនៅក្នុងសមុទ្រទឹកសាប (ទន្លេសាប) ជោរឡើងមានកម្ពស់ ៧០ ឬ ៨០ ហត្ថ។ ដើមឈើធំៗ លិចនៅសល់តែចុង ឯពួកអ្នកស្រុករស់នៅក្បែរមាត់ទឹកនោះបាននាំគ្នារើលំនៅមកជ្រកខាងក្រោយភ្នំវិញ។

ចាប់ពីខែទី ១០ ដល់ខែទី ៣ នៃឆ្នាំថ្មី គ្មានភ្លៀងមួយតំណក់ទេ នៅក្នុងសមុទ្រទឹកសាបនោះ ធ្វើដំណើរបានតែដោយកូននាវាតូចៗទេ។ ត្រង់កន្លែងទឹកជ្រៅមានជម្រៅតែត្រឹម ៣ ឬ ៥ ហត្ថប៉ុណ្ណោះ។ ពេលនោះអ្នកស្រុករើទីលំនៅទៅនៅមាត់ទឹកធ្វើការភ្ជួរដាំវិញ។ ចំពោះស្រូវដល់ទៅពេលណាទុំក៏ត្រូវពេលទឹកឡើងដល់ល្មម។ គេសាបព្រោះដាំតាមកន្លែងដីរបស់គេរក្សារៀងខ្លួន។ គេភ្ជួរស្រែដោយមិនបាច់ប្រើគោទេ។ ចបនិងកណ្តៀវរបស់គេពិតមែនតែមានសណ្ឋានប្រហាក់ប្រហែលគ្នានឹងរបស់ចិនដែរ តែមិនដូចគ្នាឡើយ។

មានស្រែព្រៃមួយបែបទៀត គេមិនព្រោះដូចស្រូវធម្មតាទេ ស្រូវដែលគេព្រោះនោះចេះលូតឡើងតាមទឹក បើទឹកឡើងដល់កម្ពស់ ១០ ហត្ថ ក៏ស្រូវលូតលាស់កម្ពស់នោះដែរ។ នេះប្រហែលជាពូជស្រូវមួយបែបផ្សេងទៀតហើយ។ ស្រែ អំពកនិងថ្នាលបន្លែ គេមិនប្រើគ្រឿងស្មោកគ្រោក ដែលជាហេតុនាំឲ្យមិនស្អាតនោះទេ។ ពួកចិនដែលទៅដល់ស្រុកនោះក៏គេមិនហ៊ាននិយាយរឿងពាងលាមកនៅប្រទេសចិនឲ្យពួកនោះដឹងដែរ ព្រោះខ្លាចគេមើលងាយ។ នៅក្នុងផ្ទះពីរបីខ្នង គេជីករណ្តៅបង្គន់អាចម៍មួយហើយគេប្រក់ស្បូវ។ ដល់កាលណាពេញទៅនោះ គេលប់ចោលវិញហើយទៅជីករណ្តៅមួយទៀត។ នៅរាល់ពេលដែលបន្ទោរបង់រួច គេតែងតែចុះទៅលាងឯក្នុងស្រះឲ្យបានស្អាតជានិច្ច តែគេយកតែដៃឆ្វេងទៅលាងទេ ឯដៃស្តាំគេទុកបរិភោគបាយ។ ពួកគេមើលឃើញជនជាតិចិនចូលបង្គន់ហើយយកក្រដាសកិត គេសើចថែមទាំងមិនចង់ឲ្យឡើងលើផ្ទះគេទៀតផង។ ស្រីៗស្រុកនេះ បត់ជើងតូចក៏ឈរដូចប្រុសដែរ ជាការគួរឲ្យអស់សំណើចណាស់។

**១៨. អំពីទឹកដី**

ចាប់តាំងពីចូលក្នុងស្រុក "ចេងផូវ" មក ខ្ញុំមើលឃើញសុទ្ធតែព្រៃឈើវែងអន្លាយ នៅតាមមាត់ទន្លេដ៏ធំធេងមានដើមឈើធំចាស់បុរាណនិងគុម្ពផ្តៅស៊ុបទ្រុបចម្ងាយរាប់រយលី ហើយមានសម្លេងបក្សាបក្សីស្រែកទ្រហឹងអឺងកងនៅទីនោះផង។ លុះទៅដល់ពាក់កណ្តាលទន្លេ ទើបមើលទៅឃើញវាលស្រែក៏ធំធេង គ្មានឃើញដើមឈើមួយដើមឡើយ គេមើលទៅឃើញតែស្រូវទុំនៅសព្វទិសទីប៉ុណ្ណោះ។

មានសត្វគោព្រៃរាប់រយរាប់ពាន់បានមកផ្តុំគ្នាជាហ្វូងនៅទីនោះ។ មានឫស្សីដុះជាប់គ្នាជាដងព្រៃ មានចម្ងាយរាប់រយលី ហើយឫស្សីទាំងនោះមានជួរបន្លានៅត្រង់គ្រប់ថ្នាំង។ ទំពាំងឫស្សីមានរសជាតិហាងខ្លាំងណាស់ ហើយនិងមានភ្នំនៅគ្រប់ទិសទាំងបួនទៀតផង។

**១៩. អំពីផលានុផល**

ស្រុកនេះមានភ្នំច្រើននិងមានដើមឈើប្លែកៗ។ កន្លែងណាដែលគ្មានដើមឈើទេគឺជាកន្លែងដែលសត្វរមាសនិងដំរីរស់នៅ។ ពពួកសត្វស្លាបដ៏មានតម្លៃនិងសត្វម្រឹគដ៏ប្លែកៗ មានច្រើនឥតគណនា។ មានសត្វចចាតពណ៌និងរោមល្អិត ភ្លុកដំរី កុយរមាស ឃ្មុំ ផ្លិតធំៗ ឈើចន្ទន៍ក្រស្នា ក្រវាញ ជ័រចុង បញ្ញើក្អែក (ជីកេង) ប្រេងសំរោង (តៃហ្វងជី)...។

ចចាតជាសត្វមួយបែបគេកម្រចាប់វាបានណាស់។ នៅក្នុងព្រៃមានស្រះប្បុតពាំង ហើយនៅក្នុងទឹកនោះមានត្រីជាច្រើន ។ សត្វចចាត វាហើរចេញពីព្រៃមកចាប់ត្រីនោះជាអាហារ។ ពួកអ្នកព្រៃ គេយកស្លឹកឈើបិទបាំងខ្លួន ហើយទៅអង្គុយនៅក្បែរមាត់ទឹក។ គេយកមេចចាតផ្ទាក់មួយដាក់ក្នុងទ្រុង ដើម្បីនឹងបញ្ឆោតចាប់យកចចាតឈ្មោល គឺនៅនឹងដៃគេមានកាន់កូនលប់មួយទៀត រង់ចាំកាលណាចចាតឈ្មោលនោះមកជិត គេក៏គ្របលប់នោះយកវា។ គេធ្វើរបៀបនេះក្នុងមួយថ្ងៃទាល់ល្ងាច ជួនកាលចាប់ឥតបានសោះក៏មានដែរ។ ភ្លុកដំរីមានតែអ្នកដែលនៅក្នុងរូងភ្នំឆ្ងាយដាច់ស្រយាលពីគេទើបរកបាន។ ដំរីមួយស្រុតស្លាប់ទៅនៅសល់តែភ្លុកមួយគូប៉ុណ្ណោះ។ ដូច្នេះពាក្យដែលគេធ្លាប់និយាយថា សត្វដំរីក្នុងមួយឆ្នាំប្តូរភ្លុកម្តងនោះមិនពិតទេ។ ភ្លុកណាដែលចាក់នឹងច្បូកឬលំពែងបានមក គេទុកជាភ្លុកល្អលេខមួយ បើភ្លុកដែលគេបានដោយឃើញវាស្រុតស្លាប់ខ្លួនវាភ្លាមគេចាត់ជាភ្លុកល្អលេខពីរ បើគេរើសបានដោយដំរីស្លាប់យូរឆ្នាំចោលនៅក្នុងរូងភ្នំ គេចាត់ជាធុនអន់ជាងគេ។

ក្រមួនឃ្មុំ គេរកបានពីដើមឈើចាស់ៗ នៅក្នុងភូមិដែលសត្វឃ្មុំមួយប្រភេទមានចង្កេះស្តួចឆ្មារដូចសត្វអង្ក្រង វាធ្វើ សម្បុក។ អ្នកស្រុកដែលទៅយកឃ្មុំតាមទូកតូចៗ គេអាចដាក់បានពីរបីពាន់ផ្លិត។ ផ្លិតណាដែលធំជាងគេមានទម្ងន់ដល់ទៅ ៣០-៤០ នាឡិ ឯផ្លិតណាដែលតូចក៏មិនតិចជាង ១៨ ឬ ១៩ នាឡិដែរ។

កុយរមាសណាដែលពណ៌សហើយមានផ្កា គេចាត់ទុកជាកុយល្អ ហើយបើខ្មៅវិញ គេទុកជាកុយអន់មិនសូវល្អ។

ឈើចន្ទន៍ក្រស្នាដុះតែនៅក្នុងព្រៃស្បាត ព្រៃស្លុក។ អ្នកស្រុកទៅកាប់យកមកបានដោយពិបាកណាស់ ព្រោះថាឈើដែលមានខ្លឹម។ ឈើនេះមានសាច់ស្រាយកម្រាស់ ៨ ឬ ៩ តឹក។ ទោះបីដើមតូចក៏មានសាច់ស្រាយ ៤ ឬ ៥ តឹកដែរ។

ក្រវាញ គឺជាពួកអ្នកព្រៃ គេដាំនៅលើភ្នំ។

ជ័រចុង គឺជាជ័រឈើមួយយ៉ាងដែលអ្នកស្រុកនេះគេយកកាំបិតទៅចោះឈើសម្រក់ជ័រមុនមួយឆ្នាំ ដល់ឆ្នាំបន្ទាប់មកទើបគេទៅយកជ័រនោះមក។ បញ្ញើក្អែកជីកេង (អ័រគីដេ?) ដុះនៅលើមែកឈើមួយប្រភេទដូចគ្នានឹងដើមមនដែលដុះ ផ្ញើសាំនឹងគេដូច្នេះដែរ ហើយគេកម្រនឹងរកបានណាស់។

ប្រេងសំរោង គេយកមកពីផ្លែឈើដើមធំមួយប្រភេទដែលមានសណ្ឋានដូចផ្លែដូងល្អិតមូលៗ។ នៅក្នុងផ្លែនោះ មានគ្រាប់ជាច្រើនទៅទៀត។ ឯម្រេចដុះព័ទ្ធលើដើមផ្តៅមួយគូ មានពណ៌បៃតងដូចផ្លែស្ពៅ បើនៅខ្ចីពណ៌ក៏ខ្ចីនិងរិតតែហិរណាស់ផង ។

**២០. អំពីរបរជំនួញ**

អ្នកស្រុកនេះពួកស្រីៗ ប៉ិនជួញដូរណាស់ ហេតុនេះពួកចិនៗគេត្រូវរកប្រពន្ធមួយជាមុនសិន ហើយនឹងបានចំណេញច្រើនដោយគេប៉ិនប្រសប់រកស៊ី។ រាល់ថ្ងៃគេទៅលក់តាំងពីភ្លឺព្រាងៗ ដល់ពេលថ្ងៃត្រង់ទើបឈប់ ហើយពួកនេះគ្មានគ្រែឬផ្ទះសម្រាប់ដាក់លក់ឥវ៉ាន់ទេ គេច្រើនតែក្រាលវត្ថុហាក់ដូចជាកន្ទេលផ្ទាល់ទៅនឹងដីតម្រៀបគ្នា។ ខ្ញុំឮគេថាមានបង់ឈ្នួលដីជាលុយឲ្យពួកមន្ត្រីទៀតផង។

ជំនួញតូចតាចគឺគេជួញស្រូវអង្ករនិងរបស់ដែលផ្ញើមកពីស្រុកចិន។ បន្ទាប់មកមានលក់ដូរកំណាត់សំពត់ផ្សេងៗ។ ជំនួញធំគឺគេជួញមាសប្រាក់។ តាមធម្មតាពួកអ្នកព្រៃតែឃើញពួកចិនទៅដល់ គេគោរពចិនសម្បើមណាស់ ទុកដូចបានជួបនឹងព្រះ ហើយក្រាបក្បាលគោរពទៀតផង។ លុះមកដល់ពេលថ្មីៗនេះ ទើបមានការបោកប្រាស់និងមើលងាយចិន ដោយហេតុមកពីមានមនុស្សទៅច្រើនពេក។

## ២១. ទំនិញចិនដែលគេត្រូវការ

អ្នកស្រុកនេះគ្មានកើតមាសកើតប្រាក់ទេ គេនឹកឃើញតែមាសមកពីស្រុកចិន គឺមាសប្រាក់ជាផលលេខ១ កំណាត់មានពណ៌ទាំងប្រាំជាលេខ ២។ បន្ទាប់មកគេត្រូវការសំណមកពីស្រុកចេងជីវ ថាំងតែស្ពាច់មកពីស្រុកអ៊ូជីវ ថូផ្កាពណ៌មកពីស្រុកជួរជីវ និងទឹកប្រាក់ ជាតិហិង្គុល ក្រដាសសរសេរ ស្ពាន់ធ័រ ថ្មដុត ឈើក្រអូប ឫសប៉េកជី ក្រលៀនប្រើស សំពត់ សរសៃធ្មៃ សំពត់ហ្វាងឆាវ ឆ័ត្រ ឆ្នាំងដែក ថាស់ស្ពាន់ គជ ម្រ័ក្សណ៍ ក្រាសឈើ ម្ជុល ជាដើម។ ក្រៅពីនេះ របស់ដែលធំៗ ដូចជាកន្ទេលស្រុកម៉េងជីវ ដែលគេពេញចិត្តបំផុតគឺមានសញ្ញារូបម្ទេស តែគេមិនងាយនឹងយកទៅបានទេ។

## ២២. អំពីស្មៅ និង ដើមឈើ

មានដើមទទឹម អំពៅ ផ្កាឈូក ក្រអៅឈូក ផ្ទៃខេមម៉ា ចេក ដូចនៅស្រុកចិនដែរ។ គូលែននិងក្រូចឃ្វិច ក៏មានរាងរៅដូច តែជូរ។ ក្រៅពីនេះ មានឈើព្រៃជាច្រើនដែលប្រទេសចិនយើងមិនធ្លាប់ដែលឃើញ ហើយប្លែកៗទៀតផង។ មានផ្កាជាច្រើនដែលល្អៗ ហើយមានក្លិនក្រអូបណាស់។ ផ្កាដែលដុះនៅក្នុងទឹកក៏មានជាច្រើនយ៉ាង តែខ្ញុំមិនស្គាល់ថាជាឈ្មោះផ្កាអ្វីទេ។ ចំណែកដើមថោ លី ហេង បួយ សុង ប៉េក សាំ ក្វាយ ឡឺ ចោ អ៊ាង លីវ គុយ ឡាង កេក លួយ ឈើប្រភេទអស់នេះគ្មានទេ។ នៅស្រុកនោះ ខែទី ១ ក៏មានផ្កាឈូកដែរ។

## ២៣. អំពីសត្វស្លាប

បណ្តាសត្វស្លាបឃើញមានក្ងោក ចចាត លលក ដែលប្រទេសចិនគ្មាន។ ក្រៅពីនេះដូចជាខ្លែង ក្អែក ត្មាត សេក ចាបស្រុក ត្រដក់ កុក ប្រវឹក និងចាបពូកជាដើម សុទ្ធតែមានទាំងអស់។ សត្វស្លាបដែលស្រុកនេះគ្មាន ដូចជា ហ៊ីងតូវ (ល្វាចេក?) ហុងអេង (ក្ងានព្រៃ) អ៊ីងអេង (ក្លែងលឿង) តូវអ៊ូ (ត្រចៀកកាំ)...។

## ២៤. អំពីសត្វជើងបួន

សត្វចតុបាទ មានរមាស ដំរី គោព្រៃ ដែលប្រទេសចិនគ្មាន។ ក្រៅពីនេះ ខ្លាធំ ខ្លាត្រី ខ្លាឃ្មុំ ជ្រូកព្រៃ ប្រើស ក្តាន់ និងកញ្ជ្រោងជាដើម សុទ្ធតែមានច្រើនណាស់។ សត្វដែលស្រុកនេះគ្មានគឺ គោ ស៊ឹងស៊ីង [៤៣] និង ឱដ្ឋ។ មាន់ ទា គោ សេះ ជ្រូក និង ពពែ មានច្រើនក្រៃលែង។ តែសេះស្រុកនេះទាបៗណាស់ គោតូចៗ ក៏មានច្រើនណាស់ដែរ។ សត្វគោនៅរស់ គេហ៊ានជិះ តែដល់វាស្លាប់ទៅ គេមិនហ៊ានស៊ីនិងមិនហ៊ានរះយកស្បែកវាទេ គេទុកឱ្យវារលួយទៅតាមចិត្តចុះ ពីព្រោះវាធ្លាប់ជួយដល់កម្លាំងមនុស្សលោក។ វាធ្លាប់តែអូសរទេះ។ ពីដើមមកមិនធ្លាប់មានក្ងានទេ ប៉ុន្តែឥឡូវនេះមានហើយ ព្រោះមាននាវាចិនទៅញយៗ គេយកពូជពីស្រុកចិនទៅ។ កណ្តុរស្រុកនេះធំៗ ដូចសត្វឆ្មា ហើយមានកណ្តុរមួយមុខទៀត មានក្បាលប្លែកពិសេសធំដូចជាក្បាលកូនឆ្កែ។

## ២៥. អំពីបន្លែបង្ការ

បន្លែមានត្រកួន ស្ពៃ គូឆាយ ត្រប់ ឪឡឹក ត្រឡាច ត្រសក់ ឃិនឆាយ។ បន្លែដែលគ្មាននោះ គឺឆាយថាវ ស្ពៃខៀវ ខូវចេង ប៉ោឡេង ជាដើម។ បន្លែដូចជាត្រប់ ឪឡឹក ត្រសក់ ត្រឡាចជាដើម តែដល់ខែទីមួយមានហើយ។ ដើមត្រប់មានដុះរាប់ឆ្នាំមិនទាន់រំលើងចោលក៏មាន។ ដើមគរខ្ពស់ៗ ជាងផ្ទះទៅទៀត អាយុជាង ១០ ឆ្នាំមិនទាន់កាប់ចោលក៏មានដែរ។ មានបន្លែច្រើនមុខទៀត ដែលខ្ញុំមិនស្គាល់ឈ្មោះ ឯបន្លែដុះក្នុងទឹកក៏មានច្រើនមុខណាស់ដែរ។

## ២៦. អំពីត្រី និង សត្វលូន

ពួកត្រីនិងអណ្តើកមានះ ត្រីរស់ច្រើនណាស់ ក្រៅពីនេះដូចជាត្រីឆ្តិននិងត្រីល្អិតៗ ឯទៀតរិតតែច្រើនណាស់ទៅទៀត មានត្រីថូវពូដែលធំនោះ មានទម្ងន់ដល់ជាងពីរនាឡិ ហើយត្រីដែលខ្ញុំមិនស្គាល់ឈ្មោះនោះក៏មានច្រើនណាស់ដែរដែលជាត្រីមកពីសមុទ្រទឹកសាប (ទន្លេសាប)។ ចំណែកត្រីទឹកប្រៃវិញ ក៏មានច្រើនមុខរាងដូចអន្ទង់និងត្រីខ្ចឹងបឹងដែរ។ ពួកអ្នកស្រុកនេះមិនស៊ីកង្កែបទេ ម្ល៉ោះហើយដល់ពេលយប់គេឃើញកង្កែបលោតច្រវាត់កាត់ផ្លូវដើរ។ អណ្តើក-កន្ធាយធំៗប៉ុនចង្អេរអុំ។ ទោះជាអណ្តើកនោះមានអាយុដល់ទៅ៦ឆ្នាំក៏គេនៅតែស៊ីវាដែរ។ បង្កងនៅស្រុកឆាណាំ (កំពង់ឆ្នាំង)មួយ មានទម្ងន់ដល់ជាងមួយនាឡិ។ ជើងអណ្តើកនៅស្រុកចេនភូមានប្រវែងជាង ៨-៩តឹក។ ក្រពើធំប៉ុនទូក។ មាននាគជើងបួនមួយប្រភេទយ៉ាងចម្លែក ឥតមានស្នែងទេ។ ចំពុះទា លៀស ខ្យង ខ្ចៅ នៅក្នុងសមុទ្រទឹកសាប (ទន្លេសាប) នោះ គ្រាន់តែលូកដៃទៅក៏យកបានភ្លាមហើយ តែខ្ញុំមិនឃើញមានក្តាមទេ ខ្ញុំស្មានថាប្រហែលជាមានដែរតែគេមិនស៊ីទេមើលទៅ[៤៤]។

## ២៧. អំពីការបិទស្រា

ស្រាស្រុកគេនេះមានបួនយ៉ាង ស្រាលេខមួយចិនហៅស្រាទឹកឃ្មុំ ដែលគេយកជាតិថ្នាំនិងទឹកឃ្មុំលាយជាមួយទឹក ហើយផ្សំធ្វើឡើង។ បន្ទាប់មកហៅតាមពាក្យអ្នកស្រុកថា ផេងកេស៊ី ដែលគេយកស្លឹកឈើមកផ្សំ គឺស្លឹកឈើឈ្មោះ ផេងកេស៊ីនេះឯង ជាឈើមួយប្រភេទ។ បន្ទាប់មកទៀត គេយកអង្ករឬបាយដែលសេសសល់ទៅបិទស្រាហៅ ប៉ាវ ឡេងកាក ព្រោះពាក្យថាប៉ាវឡេងកាកបានន័យថាអង្ករ[៤៥]។ ក្រោមពីនោះមកទៀតមានស្រាទឹកល្វៃស្ករ ដែលគេយកជាតិស្ករមកបិទឲ្យកើតទៅជាស្រា។ បើគេចូលទៅស្រុកភូមិតាមមាត់ទន្លេ គេប្រទះស្រាមួយមុខទៀតធ្វើពីទឹក ក្រចាប់ ព្រោះក្រចាប់ដុះនៅមាត់ព្រែក ហើយស្លឹកវាមានរសជាតិស្ករ ដែលគេអាចយកមកធ្វើជាស្រាបាន។

## ២៨. អំបិល ទឹកខ្មេះ ស៊ីអ៊ីវ និង មី

នៅប្រទេសនេះការធ្វើរបស់ទាំងនេះឥតមានហាមឃាត់ទេ។ តាមឆ្នេរសមុទ្រចាប់ពីចេនភូនិងប៉ាកាង[៤៦] គេធ្វើអំបិលដោយទឹកសមុទ្ទ។ នៅក្នុងភ្នំមានរ៉ែដែលគេបានជាតិថ្ម ធ្វើជាអំបិលប្រសើរជាងអំបិលសមុទ្ទទៀតនិងយកថ្មធ្វើជាវត្ថុដទៃៗ ទៀត។ ពួកអ្នក

ស្រុកនេះមិនចេះធ្វើទឹកខ្មេះតែគេ ចូលចិត្តប្រើជាតិជូរនៅក្នុងម្ហូបណាស់ គេត្រាំទឹកកាំផេង[៤៧] ធ្វើជាម្ជូរ កាលណាដើមឈើនេះកំពុងតែលាស់គេយកស្លឹកឬទងខ្ចី កាលណាមានផ្លែគេយកផ្លែវិញ[៤៧]។

គេមិនចេះធ្វើមីទេព្រោះតែគ្មានស្រូវសាលីនិងសណ្តែក។

ពួកនេះមិនចេះធ្វើដំបែគ្រាប់ទេ។ កាលណាគេបិទស្រា គេលាយទឹកឃ្មុំ និងទឹកត្រាំស្លឹកឈើឲ្យបានជាក្បាលស្រា ហើយក្បាលស្រានេះ ដូចគ្នានិងស្រាស នៅក្នុងភូមិស្រុកយើងដែរ។

## ២៩. អំពីដង្កូវនាង និង ដើមមន

អ្នកស្រុកនេះមិនចេះចិញ្ចឹមដង្កូវនាងទេ ទាំងដើមមនក៏គ្មានដាំដែរ។ ស្រីៗ មិនចេះប៉ាក់ជុលនិងដេរប៉ះឡើយ។ គេចេះត្បាញសំពត់ តែគេមិនចេះរវៃអំបោះទេ គេយកដៃត្រកួញសរសៃកប្បាសឲ្យកើតបានជាអំបោះ ហើយគេយកមកត្បាញមិនបាច់មានកីទេ។ គេចងសរសៃអំបោះម្ខាងជាប់នឹងចង្កេះគេ ហើយគេត្បាញពីចុងម្ខាងទៀត ដោយមានត្រល់ជាបំពង់ឫស្សី។ ប៉ុន្មានឆ្នាំក្រោយមកនេះមានពួកសៀមចូលមកនៅ គេក៏ដាំមន ចិញ្ចឹមនាងធ្វើសូត្រ ដោយយកពូជមកពីស្រុកសៀម។ នៅស្រុកនេះ គ្មានដើមឆ្មៃទេ មានតែដើមក្រចៅ។ ជនជាតិសៀមចេះដេរប៉ាក់ចំណាប់ បើសំពត់អ្នកស្រុកនេះរហែក គេយកមកពឹងស្រីសៀមឲ្យដេរ ប៉ះឲ្យ។

## ៣០. អំពីប្រដាប់ប្រើប្រាស់

អ្នកស្រុកធម្មតាមានផ្ទះនៅហើយ តែគ្មានតុកៅអី ចានដែកឬថាំងជាដើម ប្រើទេ គេប្រើឆ្នាំងដីសម្រាប់ដណ្តាំបាយ ហើយឆ្នាំងមួយទៀតសម្រាប់ស្ល។ គេយកថ្មបីដុំតម្កល់ធ្វើជាជើងក្រាននិងយកត្រឡោកដូងធ្វើជាវែក។ គេប្រើចានទាបមកពីស្រុកចិនសម្រាប់ដាក់បាយ ឯសម្លគេដាក់នឹងកន្ទោងស្លឹកឈើដែលកេវខ្ទាស់មិនលិចទឹកទេ។ គេយកស្លឹកក្រចាប់ធ្វើជាស្លាបព្រាដួសសម្លបញ្ចូលមាត់ កាលណាប្រើរួចគេបោះចោលទៅ។ ម្ហូបថ្វាយព្រះឬថ្វាយទេពតាក៏គេដាក់នឹងស្លឹកដូច្នេះដែរ។ គេយកគ្រឿងដែលធ្វើពីស្ពាន់សដែលដាក់ទឹកនៅក្បែរខ្លួន សម្រាប់ជ្រលក់ដៃកុំឲ្យជាប់បាយនឹងដៃ ព្រោះគេបរិភោគដោយផ្ទាល់នឹងដៃ បើគ្មានទឹកផ្សើមដៃមិនបានឡើយ។ គេប្រើផ្តិលសំរឹទ្ធិសម្រាប់ចាក់ស្រាផឹក ចំណែកអ្នកក្រប្រើផ្តិលដែលធ្វើអំពីដី រីឯពួកមន្ត្រី គេប្រើផ្តិលធ្វើពីប្រាក់ ឬមាសផងក៏មាន។ បើក្នុងឱកាសបុណ្យធំៗ ដូចជាបុណ្យជាតិវិញ គេប្រើប្រដាប់ទាំងនេះ ធ្វើសុទ្ធតែពីមាសទាំងអស់ ហើយមានរបៀបផ្សេងពិសេសទៀតផង។ នៅនឹងដីគេក្រាលកន្ទេលមកពីស្រុកម៉េងជីវ (ស្រុកចិន)ឬមួយក្រាលស្បែកខ្លាធំ ខ្លារខិន ស្បែកប្រើស រមាំង.... ពុំនោះទេ គេប្រើកន្ទេលផ្តៅ។ នៅពេលជិតៗនេះ គេទើបនឹងចេះប្រើតុទាបៗ មានកំពស់ប្រហែលមួយហត្ថ។ សម្រាប់កន្លែងគេដេក គេប្រើកន្ទេលឫស្សី តែឥឡូវនេះមានខ្លះប្រើគ្រែទាបៗខ្លះដែរហើយ ដែលជាគ្រែធ្វើមកពីស្រុកចិន។ ម្ហូបចំណី គេគ្របដោយសំពត់ ឯនៅក្នុងវាំងគេប្រើសំពត់ព្រែប៉ាក់ខិនឬខ្សែស្រយ ដែលបានមកពីពួកឈ្មួញសំពៅ ប្រទេសក្រៅនាំយកមកថ្វាយ។ ដើម្បីស្រិតអង្ករ គេមិនប្រើត្បាល់កិនទេ គេប្រើត្បាល់បុកទៅវិញ។

## ៣១. អំពីរទេះ និង អង្រឹងស្នែង

ការធ្វើអង្រឹងស្នែង គេយកឈើមួយដើមដែលកោងចំកណ្តាលអ៊ែនចុះក្រោម ចុងសងខាងឡើងលើហើយនៅចុងនោះគេឆ្លាក់ជាក្បាច់ផ្កាភ្ញីនិងមានស្រោបមាសឬប្រាក់ពីក្រៅឈើនោះផង គេហៅថាអង្រឹងដងមាស ដងប្រាក់ សម្រាប់តាមលំដាប់ថ្នាក់។ ចម្ងាយពីចុងដងប្រមាណមួយហត្ថគេ វាយដែកធ្វើជាស្រយូវម្ខាងមួយហើយគេយកសំពត់មួយផ្ទាំងយ៉ាងធំហើយក្រាស់ មកបត់ធ្វើជាត្រចៀកសម្រាប់ស៊កខ្សែភ្ជាប់ទៅនឹងស្រយូវដែកនោះ។ អ្នកជិះគេអង្គុយលើសំពត់នោះ ដៃកាន់ជាយសំពត់ផង ហើយឲ្យមនុស្សពីរនាក់ជាអ្នកសែង។ នៅក្បែរអង្រឹងស្នែងតែងតែមានប្រដាប់មួយទៀត មានសណ្ឋានដូចដំបូលទូកតែធំជាង ដ៏មានបិទបាំងដោយសំពត់ព្រែប្រាំពណ៌ ហើយមានមនុស្សបួននាក់សែងនិងមានមនុស្សដើរតាមហែពីក្រោយផង។ បើធ្វើដំណើរទៅឆ្ងាយ គេអាចជិះដំរីនិងសេះ ព្រមទាំងប្រើរទេះដែរ។ រទេះនៅស្រុកនេះ ក៏មានលក្ខណៈ ដូចរទេះស្រុកឯទៀតដែរ តែគេជិះសេះ ឥតមានកែបទេ ឯដំរីក៏គ្មានប្រដាប់សម្រាប់អង្គុយដែរ។

## ៣២. អំពីទូក-ច្រវា

អំពីទូកធំៗ សុទ្ធតែធ្វើឡើងដោយយកឈើរឹងៗ មកចាំងជាបន្ទះក្តារសិន រួចទើបវាយផ្គុំឡើងជាទូក។ មេជាងឥតមានប្រើរណារទេ គេប្រើតែដឹងហើយនិងដែកខួង ដែលជាហេតុនាំឲ្យខាតឈើនិងកម្លាំងច្រើនណាស់។ នៅគ្រប់ពេលដែលគេចង់កាត់ឈើជាកំណាត់ គេតែងយកដែកខួង មកខួងទម្លុះផ្តាច់តែម្តង ទោះជាធ្វើផ្ទះក៏ធ្វើរបៀបដូចគ្នានេះដែរ។ គេមានប្រើដែកគោលវាយធ្វើទូកដែរ។ គេយកស្លឹកឡេង (ក្រចាប់) មកប្រក់ធ្វើដំបូល ដោយយកដើមស្លាមកពុះជាបន្ទះគាបសង្កត់ស្លឹកនោះផង។ ទូករបៀបនេះ គេហៅថា “ស៊ិនណា”។ គេបិទពរទូកដោយជ័រឈើ ខ្លាញ់ត្រីលាយនឹងកំបោរ។ ចំណែកទូកតូចៗវិញ គេលុងធ្វើពីឈើមួយដើមធំ។ គេយកភ្លើងដុតឆេះរោលឲ្យទន់សាច់ឈើ ទើបទល់បំប៉ោងពង្រីកពោះទូកឲ្យធំ ក្បាលកន្សៃស្រួច ឥតមានប្រើដំបូលទេ តែដាក់បានមនុស្សច្រើននាក់ដែរ។ ទូករបៀបនេះហៅថា “កុយ ឡាំង”។

## ៣៣. អំពីខេត្ត

ខេត្តមានទាំងអស់ជាង ៩០ គឺខេត្ត ចេងពូ (ចន្ទបូរ) ឆាណាំ (ឆ្នាំង) ប៉ាកាង (បាកាន) មុងលាង ប៉ូចស៊ី ផុវមួយ ទីហួង បាក់លុតប៉ោ ណៃកាខាំង ប៉ូចស៊ីលីជាដើម។ ក្រៅពីនេះ ខ្ញុំមិនចាំឈ្មោះទេ។ ខេត្តនីមួយៗសុទ្ធតែមានមន្ត្រីធំនៅកាន់កាប់ ហើយមានធ្វើបន្ទាយឈើជារបាំងផង។

## ៣៤. អំពីស្រុកភូមិ

នៅក្នុងភូមិនីមួយៗជួនមានវត្ត ជួនមានប្រាសាទ ហើយមានមន្ត្រីម្នាក់នៅត្រួតត្រាយ៉ាងហ្មត់ចត់។ មន្ត្រីនោះគេហៅថា បួយស៊ី។ នៅតាមផ្លូវធំៗតែងមានសាលាមួយសម្រាប់ឈប់សម្រាក គេហៅថា ស៊ិមប៉ាក់។ ប៉ុន្តែនៅពេលថ្មីៗនេះមានកើតចម្បាំងជាមួយនឹងប្រទេសសៀម ភូមិទាំងនេះក៏ប្រែក្លាយទៅជាដីវាលទៅវិញ។

**៣៥. អំពីប្រមាត់ប្រមង់**

កាលពីមុននេះតែដល់ខែទី ៨ គេតែងធ្វើការចាប់មនុស្សយកប្រមាត់ ពីព្រោះស្តេចក្រុងចាម្បក្នុងមួយឆ្នាំគេសុំយក ប្រមាត់មនុស្សមួយថូ ដែលមានចំនួនរាប់ពាន់។ នៅក្នុងពេលយប់ គេចាត់ពួកអ្នកយកប្រមាត់ (ប្រមាត់ប្រមង់?) ដើរទៅតាមផ្លូវនានាក្នុងទីក្រុងនិងក្នុងភូមិ។ បើប្រទះមនុស្សណាដើរក្នុងពេលយប់ស្ងាត់នោះ គេចាប់យកខ្សែចងក្បាលឱ្យជាប់ ហើយយកកូនកាំបិតចាក់ក្រោមឃ្លៀកខាងស្តាំ ខ្វេះយកប្រមាត់ដាក់ក្នុងថូ លុះគ្រាតែបានពេញចំនួនទើបគេយកទៅថ្វាយស្តេចក្រុងចាម្ប ប៉ុន្តែគេមិនយកប្រមាត់នៃជនជាតិចិនទេ។ ពីព្រោះមានកាលមួយឆ្នាំនោះ គេយកប្រមាត់របស់ចិនមួយទៅលាយនឹងគេ ក៏បណ្តាលឲ្យស្អុយរលួយខូចប្រមាត់នៅក្នុងថូ លែងប្រើការបានទាំងអស់ ពេលក្រោយមក គេលែងមានការដើរចាប់យកប្រមាត់ទៀតហើយ ហើយគេចាត់មន្ត្រីដោយឡែកសម្រាប់មុខងារខាងយកប្រមាត់ពីពួកក្រោមអំណាចខ្លួន ដែលតាំងឲ្យនៅជាយក្រុងក្បែរទ្វារខាងជើង។

**៣៦. អំពីរឿងចម្លែកមួយ**

នៅក្នុងកំពែងនាទិសខាងកើតមានអ្នកព្រៃម្នាក់នោះ រួមរ័ក្សជាមួយប្អូនស្រីឯងបង្កើត ក៏ស្រាប់តែជាប់ស្បែកសាច់គ្នា បេះមិនចេញរហូតដល់គ្រប់បីថ្ងៃ ឥតមានស៊ីចុកអ្វីសោះក៏ស្លាប់បង់ជីវិតទៅ។ អ្នកស្រុកខ្ញុំម្នាក់សែ "សិ" គេបានមករស់នៅស្រុកនេះរវាងសាមសិបប្រាំឆ្នាំហើយគេថា គេបានឃើញរឿងនេះច្បាស់នឹងភ្នែកពីរលើក ហើយគេថាបានជាសក្តិសិទ្ធិដូច្នេះ ព្រោះបារមីព្រះរបស់ស្រុកនេះខ្លាំងពូកែណាស់។

**៣៧. អំពីការងូតទឹក**

ប្រទេសនេះក្តៅខ្លាំងណាស់ ក្នុងមួយថ្ងៃៗ បើមិនងូតទឹកច្រើនលើកទេ គឺច្បាស់ជាអត់ទ្រាំមិនបានឡើយ ទោះបីនៅពេលយប់ក៏ជៀសមិនរួចពីការងូតទឹកម្តងឬពីរដងដែរ។ គេគ្មានបន្ទប់ទឹក គ្មានចានដែក គ្មានប៉ោតទេ។ ក្នុងផ្ទះមួយតោង មានស្រះមួយ បើពុំនោះទេគេព្រួតគ្នា ២-៣ ផ្ទះទៅងូតទឹកស្រះមួយដោយលែងខ្លួនចោល ឥតគិតពីរឿងខ្មាសគ្នាស្រីប្រុសទេ។ ប៉ុន្តែបើឪពុកម្តាយចាស់គាត់ទៅដល់ស្រះមុន ក្មេងស្រីប្រុសមិនហ៊ានទៅជិតទេ ប្រសិនបើក្មេងកំពុងតែងូតទឹកស្រះនោះមុនវិញ ក៏ចាស់ទុំនោះ នាំគ្នាគេចចេញដែរ។ មនុស្សមានវ័យស្របាលគ្នា ឥតគិតអៀនខ្មាសគ្នាឡើយ។ គេយកតែដៃឆ្វេងបិទបាំងកេរ្តិ៍ខ្មាសរបស់ខ្លួន ហើយដើរចុះក្នុងទឹកទៅ។ ជួនកាលក្នុងរយៈ ៣-៥ ថ្ងៃ ឬ៥-៦ថ្ងៃម្តង ពួក ស្រីៗក្នុងទីក្រុងមួយក្រុមមានគ្នា ៣-៤ នាក់ នាំគ្នាចេញទៅមុជទឹកទន្លេឯខាងក្រៅកំពែងក្រុង។ នៅពេលដែលទៅដល់ទន្លេនោះ គេដោះសំពត់ដែលវណ្ឌខ្លួនចេញ ដើរចុះទៅក្នុងទឹកហើយទៅជួបជុំគ្នានៅក្នុងទន្លេនោះរាប់ពាន់នាក់។ សូម្បីតែពួកស្រីៗដែលបានត្រកូលខ្ពង់ខ្ពស់ក៏ដូច្នោះដែរ។ គេឥតមានការអៀនខ្មាសអ្វីទេ ចាប់តាំងពីក្បាលដល់ចុងជើងមើលគ្នាឃើញទាំងអស់។

នៅមាត់ទន្លេរក្រៅទីក្រុងនោះ រាល់ថ្ងៃតែងតែមានជនជាតិចិននៅទំនេរ ហើយលួចនាំគ្នាទៅចាំមើលលេងតាមគំនិតខិលខូច ហើយឮថាគេលួចឆ្លៀតពេលនៅក្នុងទឹកនោះផង។ ទឹកនោះនៅក្តៅឧណ្ហៗជានិច្ច លុះត្រាដល់ពេលយប់យាមបួនទើបត្រជាក់លុះដល់ព្រឹក ថ្ងៃរះឡើងក៏ក្តៅឧណ្ហៗឡើងវិញទៀត។

**៣៨. ការចូលជ្រកនៅ [អន្តោប្រវេសន៍]**

ពួកជនជាតិចិនដែលជាអ្នកស៊ីឈ្នួលដើរសំពៅ កាលមកដល់ស្រុកនេះក៏ពេញចិត្តគេខ្លាំងណាស់ ព្រោះស្រុកនេះមិនបាច់ប្រើសម្លៀកបំពាក់ច្រើន ហើយអង្ករគេក៏ស្រួលរក ប្រពន្ធក៏ស្រួលរកបាន ឯផ្ទះសំបែងក៏ងាយធ្វើ គ្រឿងប្រើប្រាស់ក៏ងាយរក ការលក់ដូរក៏ធូរងាយ ម្ល៉ោះហើយបានជាមានអ្នកចូលពីស្រុកក្រៅមករស់នៅស្រុកនេះច្រើនណាស់។

**៣៩. អំពីកងទ័ព**

កងទ័ពក៏ធ្វើដំណើរដោយលែងខ្លួនឥតអាវ។ ដៃស្តាំគេកាន់លំពែង ដៃឆ្វេងកាន់ខែល គ្មានប្រើធ្នូនិងព្រួញទេ កាំភ្លើងធំឬអាវក្រោះក៏គ្មានដែរ។ តាមឮគេថា កាលកើតចម្បាំងនឹងជាតិសៀមគេនាំគ្នាកេណ្ឌអ្នកស្រុកទៅវាយដោយកម្លាំងតែម្តង ពុំមានប្រើល្បិចកលឧបាយអ្វីឡើយ [៤៨]។

**៤០. អំពីការយាងចេញនៃមហាក្សត្រ**

ខ្ញុំបានឮគេនិយាយថា ស្តេចអង្គមុនៗមិនដែលយាងចេញទៅណាទេ ព្រោះខ្លាចមានរឿងហេតុ។ ស្តេចអង្គថ្មីនេះ ត្រូវជាសុណិសាស្តេចមុន[៤៩]។ កាលពីដើម លោកមានឋានៈជាមេទ័ព។ បិតាក្មេកនោះសព្វព្រះទ័យនឹងបុត្រីព្រះអង្គណាស់បានជាកូនស្រីនេះលួចយកព្រះខ័នមាសបាន ហើយយកទៅឲ្យប្តីរបស់ព្រះនាង។ បុត្រាបង្កើតក៏មិនបានទទួលរាជ្យស្នងបិតា ក៏លើកទៅវាយដណ្តើមរាជ្យ តែត្រូវស្តេចថ្មីជ្រាបការទាន់ ចាប់បាននាំយកមកកាត់ម្រាមជើង ហើយយកទៅដាក់គុកងងឹត។ ស្តេចថ្មីនេះមានពាក់អាវក្រោះដែក ទោះបីគេប្រើកាំបិតឬព្រួញក៏មិនអាចមុតបានដែរ។ ដូច្នេះហើយទើបព្រះអង្គហ៊ានយាងចេញក្រៅ។ ខ្ញុំបានទៅនៅទីនោះជាងមួយឆ្នាំ បានឃើញព្រះអង្គយាងចេញមកបួន-ប្រាំដង។ ការយាងចេញមកម្តងណាតែងមានទ័ពនៅការពារពីខាងមុខ មានអ្នកកាន់ទង់ជ័យនិងមានតន្ត្រីនៅខាងក្រោយ។ ស្រីស្នំប្អូនឬប្រាំនាក់ស្លៀកសំពត់ផ្កា សៀតផ្កានៅសក់ក្បាល ដៃកាន់ទៀនធំដើរជាមួយក្រុមៗ។ ទោះបីនៅពេលថ្ងៃភ្លឺក្រឡែតក្តីក៏គេអុជទៀនដែរ។ នៅក្នុងចំណោមស្រីស្នំទាំងនោះ មានខ្លះកាន់គ្រឿងមានដូចជាភាជន៍មាសនិងគ្រឿងបិទបាំងជាដើមផ្សេងៗពីគ្នា មិនដឹងជាគេយកទៅប្រើការអ្វីខ្លះឡើយ។ នៅមានស្រីស្នំខ្លះទៀតកាន់ស្នរ លំពែង ខែលជាទ័ព នៅខាងក្នុងមួយក្រុមទៀតផង មានរទេះទឹមពពែនិងរទេះទឹមសេះ ដែលមានតាក់តែងដោយគ្រឿងមាសបរដង្ហែដែរ។

ពួកនាម៉ឺនសព្វមុខមន្ត្រីនិងពួកញាតិវង្សសុទ្ធតែជិះដំរីនៅខាងមុខ បើមើលពីចម្ងាយទៅឃើញសុទ្ធតែក្លស់ពណ៌ក្រហមឥតគណនា។ បន្ទាប់មកទើបដល់ព្រះមហេសីធំ-តូចតាមលំដាប់ថ្នាក់ ជិះអង្រឹងស្នែង ជិះរទេះសេះ ឬជិះដំរីធំ មានក្លស់បើកបាំងមិនតិចជាងមួយរយទេ។ បន្ទាប់មកទៀតទើបដល់ព្រះរាជាទ្រង់ឈរនៅលើខ្នងដំរី ព្រះហស្តកាន់ព្រះខ័នទិព្វ។ ភ្លុកដំរីព្រះទីនាំងសឹងមានពាក់ចង្កំមាស។ មានក្លស់ស(ស្វេតច្ឆត្រ) ចំនួន ២០ ដោយមានស៊ុមមាសបើកបាំងជុំព្រះអង្គដែលសុទ្ធតែជាក្លស់ដងមាស នៅជុំវិញព្រះអង្គមានទ័ពដំរី ប្រដាប់ដោយអាវុធជាគ្រឿងការពារ។ បើប្រសិនជាស្តេចយាងទៅណាជិតៗទេ ទ្រង់គង់លើគ្រែស្នែង (ព្រះវរ) ហើយអ្នកសែង

សុទ្ធតែស្រីៗស្អំ។ សឹងតែរាល់ដង កាលណាស្តេចយាងចេញដំណើរតែងមានរូបស្តូបតូចមួយ ហើយពីមុខនេះមានព្រះពុទ្ធរូបមាសមួយអង្គផងសែងពីមុខព្រះរាជា។ បណ្តាជនដែលនៅតាមដងផ្លូវ ត្រូវសំពះលុតជង្គង់ក្រាបក្បាលដល់ដីដែលគេហៅថា សាំប៉ា (សំពះ?) បើពុំធ្វើដូច្នោះទេ នឹងត្រូវគេចោទថាមើលងាយព្រះចេស្តា ហើយនឹងត្រូវគេចាប់យកទៅឃុំចោលឥតដោះលែងឡើយ។

ក្នុងមួយថ្ងៃ ព្រះរាជាទ្រង់កិច្ចការរដ្ឋពីរលើក គឺទទួលសវនាការពីរដ្ឋមន្ត្រីនិងរាស្ត្រ ប៉ុន្តែគ្មានបញ្ជីកត់កំណត់ចំនួនមនុស្សនិងកិច្ចការនោះទេ។ បើមន្ត្រីឬរាស្ត្រណាចង់ចូលគាល់ ត្រូវតែចូលទៅអង្គុយបត់ជើងផ្ទាល់នឹងដីរង់ចាំជាមុន។ មួយសន្ទុះក្រោយមកទើបគេឮសូរសម្លេងតន្ត្រីរងំពីខាងក្នុង។ អ្នកនៅខាងក្រៅផ្លុំស័ង្ខតបទៅវិញ។ ខ្ញុំឮគេថា គេប្រើតែទីនាំងក្រែស្នែងមាស (ព្រះវរមាស) ទេ បើគ្រាន់តែយាងជិតៗ។ បន្តិចមកគេឃើញស្រីស្អំពីរនាក់រូតវាំងននព្រះវរនោះឡើង ក៏លេចឃើញស្តេចគង់ឈរកាន់ព្រះខ័ននៅក្នុងស៊ុមមាសជាទីព្រះទែនគង់ប្រថាប់។ ពេលនោះទាំងមន្ត្រី ទាំងរាស្ត្រសុទ្ធតែឱនក្បាលលើកដៃសំពះ លុះត្រាតែផុតសម្លេងស័ង្ខដែលជាសញ្ញាឲ្យងើបមុខឡើងទើបហ៊ានងើបព្រមគ្នា។ ស្តេចក៏គង់ប្រថាប់ដែរ។ ព្រះទែននោះក្រាលដោយស្បែកសត្វសិង្ហ ដែលជាកេរ្តិ៍តំណមកច្រើនស្តេចហើយ។ លុះទ្រង់ប្រស្រ័យការចប់ហើយ ស្តេចយាងចូលវិញដោយមានស្រីស្អំពីរនាក់រូតរនាំងបិទដូចដើម អ្នកទាំងអស់គ្នាក៏ក្រោកឈរហើយអែបៗខ្លួនទៅកៀនរៀងខ្លួនទៅ។

ពិតមែនតែស្រុកនេះមិនសូវស៊ីវិល័យ តែគេស្គាល់ច្បាប់ទម្លាប់គោរពព្រះមហាក្សត្រ។

១- អានតាមសម្តេចចិនទាជីវ បើអានតាមសម្លេងប៉េកាំងៈ ចូវតាក្វាន់ តែយើងធ្លាប់ហៅមកថា ជីវ តាក្វាន់ៗ។
២- សន្តតិវង្ស ងន់ នេះ មានស្តេចច្រើនអង្គ តែនេះក្នុងគ.ស. ១២៩៥ គឺត្រូវលើស្តេចឈ្មោះ ងន់ សេងចុង នាមសម្រាប់រាជ្យ ងន់ ចេង។
៣- ស្រុកវេងតា នៅក្នុងខេត្តចាក់កាង (ចិនខាងត្បូង)។
៤- សន្តតិវង្សប៉េង ចូលមកក្នុងសតវត្សទី ១៣ - ១៤ ខែ គ.ស.។
៥- នៅក្នុង ខេត្តហោណាំ (ហូណាន់)
៦- នៅខេត្តជាក់កាងដែរ
៧- លោក Pelliot សង្ស័យថា ពោធិសាត់ ប្រែពិតគឺភូមិ "ត្រៃភព" ព្រោះជាពាក្យសម្គាល់នាមព្រះពុទ្ធដែរ។
៨- ពាក្យ ទលេ បាលីប្រែជាសមុទ្រ សព្វថ្ងៃ ក្លាយជា ទន្លេសាប វិញ។
៩- ត្រង់នេះ តាមសេចក្តីប្រែលោក Pelliot មិនឮថា ព្រមចំណុះចុះចូលទេ តែនេះប្រែតាមប្រយោគចិនថាៈ 遂得臣服 ដូច្នេះហើយនេះបានត្រឹមតែ ថាគេព្រមរាក់ទាក់ទទួលបេសកជនប៉ុណ្ណោះ។
១០-ពស់ធំនេះ បើខ្មែរគឺជា នាគ។ ជីវ តាក្វាន់ ធ្លាប់ស្គាល់នាគចិន មានរូបផ្សេងពីពស់ បានជាហៅនាគខ្មែរថា ពស់។

១១- លោក P.Pelliot ចុះសេចក្តីយល់ថាប្រាសាទនេះ គឺជាប្រាសាទបាយ័ន
១២- តាមសេចក្តីប្រែរបស់ P. Pelliot ថា Lou Pan ហើយលោកចុះសេចក្តីយល់ថាជាប្រាសាទអង្គរវត្ត។ តាមចិន លូប៉ូន ជាឈ្មោះមេជាងរចនាក្នុងរឿងព្រេង (ដូចខ្មែរយើងនិយាយពីពិស្ណុការអ្នកសាងប្រាសាទដែរ)។
១៣- លោក P.Pelliot យល់ថាជាប្រសាទមេបុណ្យខាងលិចដែលគាត់បន្ថែមថា ប្រហែលជាគេច្រឡំ ជាទិសខាងកើតទៅវិញ។
១៤- ទំនងជាប្រាសាទនាគព័ន្ធ។
១៥- ត្រង់នេះគឺជាបុស្បុកមួយ ដែលមានសសរបួន និងក្បាច់លំអរដោយកញ្ចក់ ជើងទ្រធ្វើជារូបដំរី តែលោក ជីវ-តាក្វាន់ សរសេរថា ជាស៊ុមមួយ ព្រោះឃើញមាន តែមគ្របជុំវិញ។
១៦- ពស់ក្បាលប្រាំបួននេះ គឺជានាគ ព្រោះនាគខ្មែរមានខ្លួនជាពស់ ឯនាគចិនមានជើងនិងក្បាលតូច ឥតពពារទេ។
១៧- តាមសេចក្តីប្រែរបស់លោក Pelliot ថា ប៉ាឃី។ ពាក្យនេះទំនងជាមកពីពាក្យ "បណ្ឌិត"។
១៨- លោកសង្ឃខាងពុទ្ធសាសនា ប្រហែលមកពីពាក្យចៅគូ។
១៩- លោក Pelliot ប្រែថា ប៉ាសីវ៉េ។ ប្រហែលមកពីពាក្យ "បស្វះ" ឬ "បស្វិ"។
២០- តាមមហាយានគេជឿថាមានព្រះពុទ្ធពីរអង្គ គឺព្រះពុទ្ធដើមនៅឋានសួគ៌ នាម"អាមិតាភៈ" និងព្រះពុទ្ធដែលត្រាស់ដឹងនៅស្ថានមនុស្សនាម "សក្យមុនី"។

២១- បានជាខ្ញុំប្រែថា តាលព្រឹក្ស ព្រោះពាក្យដើម គេពុំទាន់បញ្ជាក់ច្បាស់ថា ស្លឹករឹតនៅឡើយទេ។
២២- ការពិតគេចារដោយដែកចារ ហើយយកធ្យូងលាយប្រេងមកលុប ទើបបានជាស្នាមខ្មៅនេះ។
២៣- លោក Pelliot ចុះសេចក្តីយល់ថា ជា លិង្គ។
២៤- ស៊ុមមាសនេះហើយ ដែលយើងស្គាល់ម្តងមកហើយ ហើយយើងសន្និតថា ជាបុស្បុកដែលជាទីប្រថាប់ក្នុងក្រឡាព្រះគំនាល់។
២៥- បូយឆេង ប្រែថា មន្ត្រីទិញ គឺពួកដែលគេទិញដាច់មិនឲ្យទៅនៅមានប្រពន្ធកូនឡើយ។
២៦- ពរនេះបានន័យថាឲ្យមានគេស្រឡាញ់ច្រើន ដូចទម្លាប់ពួក កួយ - ព្នង បើមានកូនក្រមុំ គេឲដេកនៅផ្ទះបាយ ទុកឱកាសពេលយប់ឲកំឡោះៗទៅស្ទាបលលួងចុះ។
២៧- ឆឹនថាន់ នេះមិនដឹងជាពាក្យដើមថាអ្វី រកប្រែឲជាន័យច្បាស់ពុំទាន់រឃើញ។
២៨- ត្រង់នេះ អត្ថបទដើមក៏និយាយមិនច្បាស់សេចក្តីដែរ យើងប្រែឲ្យនៅន័យត្រឹមតាមឃ្លា : 親以手去其童， 納之酒中 ។ត្រង់នេះលោក Pelliot ប្រែថា : Il la déflore avec la main et recueille ses prémices dans du vin។ អ្នកបកប្រែសុំបញ្ជាក់ថាៈ រឿងរ៉ាវក្នុងវគ្គនេះពុំដែលឮក្នុងទំនៀមខ្មែរទេ ប៉ុន្តែយើងប្រែតាមតែអត្ថបទដើមប៉ុណ្ណោះមិនហ៊ានបំបាត់ចោលឡើយ។
២៩- មនុស្សព្រៃនេះ គឺពួកអ្នកស្រុកដើមដែលរស់នៅដោយ ព្រៃមិនទាន់បានទទួល ស៊ីវិល័យ គេកៀរចាប់មកលក់។
៣០- លោក Pelliot ក៏សន្និដ្ឋានថា ពាក្យនេះមកពី "ជង" ដែរ ហើយអះអាងថាជាពាក្យដែលអានតាមសម្លេងចិនក្នុងសតវត្សទី ១៣។
៣១- លោក Pelliot បន្ថែមន័យថា Bande d'étoffe ពុំដឹងជាមានកំណត់ប៉ុន្មាន តែនេះ យើងប្រែតាមពាក្យដើមថា ប៉ូវ ដែលប្រែថា កំណាត់សំពត់។
៣២- 巴馳 ទំនងជាមកពី ប៉ាតាវ ដែលនៅសល់ក្នុងភាសាជនជាតិដើមចារ៉ាយហៅ ឪពុក។
៣៣- សម្លេងចិនអានថា "មី" សំដៅពាក្យហៅម្តាយថា "មេ"។
៣៤- ប៉ាតេងពីស៊ុ = មន្ត្រីចិន។ ប៉ានឃាបពីស៊ុ = អ្នកប្រាជ្ញចិន។
៣៥- លោក Pelliot ប្រែត្រង់នេះថា Ecriture។ តែន័យយើងថានេះ ទូលាយជាង ព្រោះតម្រូវតាមអក្សរចិន: 文字 ។
៣៦- ត្រង់នេះ លោក Pelliot ថាហៅថា "សូ" ទៅវិញ។ តែបើតាមឮចាស់ៗនិយាយតៗមកថា គេសរសេរនឹងដីសពង គឺដីសុទ្ធ តែសដូចម្សៅ។
៣៧- បានជារាប់ពីខែកត្តិក ព្រោះជំនាន់ដើមគេរាប់រនោចមុនខ្នើត គឺពីមួយរោចខែកត្តិកទៅជាដើមឆ្នាំ ខែលេខ១។
៣៨- លោក Pelliot ប្រែថា Ya-lie ហើយចុះសេចក្តីយល់ថា Rap Riep។
៣៩- លោក Pelliot ថា Gnai-lan (Ram)។
៤០- ការពិតយើងលើកតែខែទី ៨ គឺខែអាសាឍ ប៉ុន្តែនេះ គឺលោកជីវតាក្វាន់និយាយតាមខ្មែរជំនាន់ដើម ដែលគេរាប់ពី១រោច ខែអាសាឍទៅដល់ ១៥ កើត ខែស្រាពណ៍ចាត់ជាខែទី ៩។
៤១- គុកសួគ៌ៈ គឺថាទុកដូចជាគុកមួយដែលសក្តិសិទ្ធិដូចទេពតាមកកាត់ក្តីនេះឲ្យ។
៤២- លោក Pelliot ប្រែថាឃ្លង់ប៉ុន្តែតាមន័យអក្សរចិន នេះប្រែឲ្យចំគឺស្រែង។ បើថាឃ្លង់ដូចជាមិនមែន ព្រោះកើតឃ្លង់ឯណាដល់ទៅពេញស្រុក បើឃ្លង់មែនមិនងាយមើលជាទេ។ បើថាស្រែងនោះសមមែន ព្រោះជម្ងឺនេះច្រើនបណ្តាលពីការកខ្វក់។
៤៣- ស៊ីងស៊ីង គឺជាស្វាមាឌធំប៉ុនមនុស្ស ដូចគេធ្លាប់ហៅតាមកុនថា ស្វាគីងកុង។
៤៤- ការពិតស្រុកយើងមានក្តាមច្រើនណាស់ពីដើមមក តែប្រហែលជាលោក ជីវ តាក្វាន់ មិនប្រទះឃើញក្នុងទន្លេ។
៤៥- អង្គរពីដើមគេហៅ រង្គរ។
៤៦- ចេនភូ = ចន្ទបូរឬចន្ទបូរី។ ប៉ាកាងៈ បាកាន។
៤៧- តាមមើលទៅ ដើមនេះគួរជាដើមអម្ពិល ព្រោះគេប្រើស្លឹកក៏បាន ផ្លែក៏បាន។

៤៨- រឿងនេះ មកពី ជីវតាក្វាន់ មិនបានឃើញនិងស៊ើបពត៌មានទេ ព្រោះតាមឯកសារជាច្រើនណាស់ ថាខ្មែរចេះរៀបចំទ័ពត្រឹមត្រូវ មានសស្ត្រាវុធនិងក្បួនយុទ្ធសាស្ត្រផង។
៤៩- ស្តេចអង្គនេះ លោក A. Leclère សរសេរក្នុង Histoire du Cambodge ថា៖ ក្នុងចន្លោះពេលនោះ មានស្តេចសោយរាជ្យជាច្រើនអង្គ មិនប្រាកដនាម តែគេសម្គាល់បានមួយតាមសិលាចារិក គឺស្តេចជយបរមេស្វរៈ ដែលសោយរាជ្យក្នុងចន្លោះឆ្នាំ ១២៥០ ដល់ ១៣០០ នេះ។

## ពន្យល់ពាក្យខ្លះដែលជាសំដីខ្មែរ

## ហើយ ជីវ តាក្វាន់ កត់ជាអក្សរចិន

(រៀបតាមលំដាប់អក្សរ)

**កាងពាងឈូ ឬ កាងពាងជូ** = 干傍取

តាមយោបល់លោក Pelliot ថា ពាក្យកាងពាងក្លាយពីពាក្យ កំពង់ ៗ តាមយោបល់យើងថា កំពង់ចិនសរសេរតែមួយម៉ាត់ទេថា ប៉ុង ដូចជាប៉ុងថាំ 磅針 ៖ កំពង់ចាម។ ម្យ៉ាងទៀត បើកាត់យកតែពីរម៉ាត់ ត្រូវនៅសល់មួយម៉ាត់ទៀត ឈូឬជូ ប្រែមិនកើត ។ ដូច្នេះ យើងយល់ថា ពាក្យនេះទំនងជាមកពីពាក្យ កំពែងជួរ ទៅវិញ ព្រោះពីដើមទីក្រុងនីមួយៗ តោងធ្វើជាកំពែងជាជួរព័ទ្ធជុំវិញ ជាព្រំដែននៃទីក្រុង។ ក្នុងបរិវេណនៃកំពែងនេះ អ្នកក្រុងរស់នៅ មានវាំង មានផ្សារផ្សេ មានផ្ទះអ្នកទីក្រុង។ ទម្លាប់បុរាណ ហៅថា កំពែង ឬ សិមា។ សូមមើលពាក្យលោក សុត្តន្តប្រីជា-ឥន្ទ ក្នុងគតិលោកទី ១ ក៏និយាយហៅទីក្រុងថា កំពែង។ នៅសិលាចារឹកជាច្រើន ក៏ហៅទីក្រុងថា កំពែង។ លោក Pelliot បានប្រែកាងពាងជូថា Ville murée ក៏សមន័យថាកំពែងនេះដែរ។

**កានពូចឺ ( ចិនទាជីវអាន : កាំព័រទី )** = 甘孛智

ជាសម្ដីចិនកត់តាមសម្ដីខ្មែរថា ៖ កម្ពុជ ឬ កម្ពុជា។ ហេតុនេះហើយ បានជាចិនដែលសរសេរក្រោយជីវ តាក្វាន់ កែទៅជាកាំផូវជិ = 澉浦只 ដូច្នេះក៏មាន។ ហើយក្រោយមកទៀត កែទៅជា កាំពូចេ = 柬埔寨 ដែលនៅប្រើជាប់រហូតសព្វថ្ងៃនេះ។ ជីវ តាក្វាន់បានបញ្ជាក់ក្នុងសេចក្ដីផ្ដើមថា តាមការកត់ត្រារបស់ពួកអឺរ៉ុបថា ប្រទេសនេះឈ្មោះដូច្នេះដែរ។ ត្រង់នេះនាំឲ្យយើងដឹងថា ជីវតាក្វាន់ បានមើលសៀវភៅកំណត់ហេតុរបស់អឺរ៉ុប គឺពួកព័រទុគេស៍ ដែលសរសេរឈ្មោះប្រទេសយើងថា Kamboja ឬ Kamvuja (កម្វុជ ) ( សូមមើលសៀវភៅ Le Cambodge)។

**ឃុនលុន** = 崑崙

ឈ្មោះសមុទ្រដែលលោកជីវតាក្វាន់និយាយថា នៅតាមរយៈផ្លូវពីក្រុងចាម្បមកស្រុកចេនឡា។ លោក Pelliot ស្រាវជ្រាវឃើញថា ជាសមុទ្រកោះត្រឡាចដែលលោកប្រែ = La mer de Poulo-Condor ប៉ុន្តែយើងស្រាវជ្រាវតាមរកឲ្យឃើញន័យច្បាស់ជាងនេះទៀតពុំទាន់ឃើញ។

**ចេនគាឡាង ឬ តាំងកេឡាង** = 陳家蘭

ទំនងជាពាក្យសំស្ក្រឹត ស្រីគារដែលខ្មែរនិយមយកមក ប្រើហៅពពួកស្នំបរិវារនិងអ្នកបម្រើស្ដេច សម្រាប់ហែហមជាលំអ និងជាកិត្តិយសស្ដេច។ យើងសរសេរសព្វថ្ងៃទៅជា “ស្រីង្គារ”។

មកពីដំបូងគេអានថា សឹងគារៈ មានសម្លេង រៈ នៅចុង លុះចិនគ្មានអក្សរ រ ក៏យកសម្លេង ឡឬល មកជំនួសបានជា សឹគារៈ ទៅជា ចេន គា-ឡាង។

**ចេងផូវ ឬ ចេងភូ**

លោកជីវតាក្វាន់ទុកជាឈ្មោះស្រុកមួយ ជាជាយដែនប្រទេសចេនឡា។ លោក Pelliot បញ្ជាក់ថែមថា ស្រុកនេះនៅត្រង់ភូមិភាគ Cap Saint-Jacques ឬខេត្តបារៀ សព្វថ្ងៃនេះ ។

**ចេនឡា ឬ ចេនឡាក់** = 真臘

ពាក្យនេះនៅក្នុងការរាវរកសំខាន់ណាស់ ព្រោះជាឈ្មោះប្រទេសតែម្ដង។ នឹងថាជាឈ្មោះដែលអ្នកស្រុកយើងហៅខ្លួនឯងថា យើងជាអ្នកចេនឡាឬជាតិចេនឡាក៏មិនមែន ព្រោះដូចនិយាយខាងដើមសេចក្ដីប្រែនេះស្រាប់ ដែលលោកជីវតាក្វាន់បញ្ជាក់ថា អ្នកប្រទេសនេះហៅខ្លួនឯងថា កាន់ ផៃ ចឺ ហើយដែល អ្នកស្រុកអឺរ៉ុបកត់ទុកថា កាំពូចឺ ដែលមានសម្លេងស្រដៀងនឹង កាំពូចេ ដែរ។ កំណត់នេះបង្ហាញថាមិនមែនជនជាតិយើងដាក់ឈ្មោះចេនឡានេះទេ ប្រាកដជាបរទេសហៅសម្គាល់តាមហេតុឬតាមរបស់អ្វីមួយមិនខាន ពិសេសគឺចិននេះឯងបានមកទាក់ទង ហើយបានសរសេរកត់ត្រាពីស្រុកយើងមុនគេ (តាំងពីសតវត្ស ទី ៤)។ បើដូច្នេះ យើងត្រូវរាវរកតាមសំនៀងសម្ដីចិន តើចេនឡានេះថាត្រាប់តាមសម្ដីខ្មែរថាម៉េច? ឧទាហរណ៍ ពាក្យ ហ្វូណាន ឬ ហ្វូណាម មកពីត្រាប់ ពាក្យខ្មែរថា ភ្នំ ចិនគ្មានអក្សរតម្រួត ម្ល៉ោះហើយ ភ្នំ រំលែកសម្លេងទៅជាភូណម ឬ ភូណាម។

កាលខ្ញុំទៅស្រុកចិនជួបនឹងអ្នកស្រាវជ្រាវចិនម្នាក់ឈ្មោះ ស៊ីវម៉េង គាត់ប្រាប់ខ្ញុំថា គាត់ឃើញឯកសារមួយនិយាយពីឈ្មោះចេនឡានេះ។ គឺដើមឡើយចិនហៅប្រទេសមួយ ដែលស្ថិតនៅខាងលើប្រទេសហ្វូណាន។ ប្រទេសនោះមានព្រៃក្រាស់ណាស់ហើយសម្បូរឃ្មុំយកក្រមួនធ្វើទៀន។ ពួកចិនតែងធ្វើដំណើរតាមសំពៅមកទិញដូរយកក្រមួនសុទ្ធ គឺក្រមួនយកពីឃ្មុំ ដើម្បីនាំទៅលក់ឯស្រុកគេសម្រាប់ធ្វើទៀន ហើយគេនាំគ្នាសន្មតហៅស្រុកនេះថា ៖ ក្រមួនសុទ្ធៗ គឺថា ចេន ឬ ចេង = 真 ប្រែថា = សុទ្ធ ឯឡា ឬ ឡាក់ 臘 ប្រែថា ក្រមួន ឬ ឃ្មុំ ឬ ទៀន(ភាសាចិន គេដាក់គុណនាមមុននាម) បូករួមមកបានន័យថា “ស្រុកក្រមួនសុទ្ធ”។ មានយោបល់មួយទៀតចុះសម្រុងគ្នាថា នៅច្រកទន្លេធ្លាយ ទៅសមុទ្រជាកន្លែងអ្នកចេនឡានាំក្រមួនសុទ្ធទៅទុកលក់ឲ្យសំពៅចិននោះគេសន្មតឈ្មោះស្រុកក្រមួនដែរ គឺក្រមួនស (កម្ពុជាក្រោម) សនេះមិនសំដៅក្រមួនខ្លាញ់គោទេ ព្រោះសម័យនោះមិនទាន់មាន ដូច្នេះសនេះគឺជាសុទ្ធនេះឯង ហើយនៅភូមិភាគក្រមួនសនោះ ក៏មានស្រុកភូមិមានឈ្មោះថា ក្រមួនៗ ច្រើនណាស់នាំឱ្យសន្និដ្ឋានបានថា ស្រុកភូមិត្រង់នោះជាទីឃ្លាំងផ្ទុកក្រមួននាំទៅទុកលក់ឲ្យសំពៅចិនមែន ព្រោះសំពៅដើរតែតាមសមុទ្រមិនបានចូលមកតាមទន្លេទេ។

**ឆឹនថាន ឬ ឆេនថាន់** = 陣毯

ទំនងជាមកពីពាក្យ ជាន់ឋាន ក្រែងក្នុងពិធីនេះគេនាំលោកមកកាន់ទីកន្លែងរបស់កូនស្រី ? ប៉ុន្តែក្នុងទំនៀមយើងមកឥឡូវនេះមិនឃើញមានធ្វើដូច្នេះទេ។ ពត៌មាននេះមិនគួរនឹងជឿ ប៉ុន្តែយើងយល់ថា តើលោកជីវ តាក្វាន់បំផ្លើសរឿងនេះដើម្បីប្រយោជន៍អ្វី? មិនតែប៉ុណ្ណោះ លោកបញ្ជាក់ទាំងពេលដែលឃើញគេធ្វើ ហើយត្រង់ណាលោកមិនឃើញផ្ទាល់ភ្នែក ដូចជានៅក្នុងបន្ទប់ក៏ លោកបញ្ជាក់ច្បាស់ថា លោកគ្រាន់តែឮគេថាទេ (ត្រង់នេះឃើញថា លោកមានចិត្តត្រង់ណាស់ក្នុងដំណើរកត់ហេតុនេះ )។

**ឆេណាំ ឬ ឆាណាំ** = 查南

ជាសម្លេងចិន គ្រាប់តាមពាក្យខ្មែរថាឆ្នាំង ដោយសារចិនគ្មានសម្លេងអក្សរតម្រួត គឺសំដៅយកកំពង់ឆ្នាំង ព្រោះពាក្យកំពង់ប្រែថា ភូមិ ម្លោះហើយលោកជីវ តាក្វាន់កត់យកតែឈ្មោះភូមិតែម្តង។ ច្បាស់ថែមពីលើនេះទៀត គឺលោកជីវ តាក្វាន់បានរាប់រៀបថាជាឈ្មោះខេត្តមួយនៃប្រទេសចេនឡា ហើយគេធ្វើដំណើរចេញពីនេះត្រូវឆ្លងកាត់សមុទ្រសាប (ទន្លេសាប) អស់ពេល ដប់ថ្ងៃទៀត ទើបទៅដល់ក្រុងធំ ។

**ជូគូ** = 苧姑

ក្លាយតាមសម្តីចិន ទំនងជាហៅពាក្យខ្មែរ ចៅគូ ដែលគេធ្លាប់និយមប្រើនៅចុងសតវត្សទី ១៣ សម្រាប់ហៅលោកសង្ឃ (សព្វថ្ងៃសៀមនៅប្រើនៅឡើយ)។

**ប៉ាតេង** = 巴丁

ពាក្យខ្មែរបុរាណ ម្រតេង ដែលក្រោយមកក្លាយជា កម្រតេង រួចសព្វថ្ងៃថា កម្តែង គឺសម្រាប់សម្គាល់ងារមន្ត្រីជាន់ខ្ពស់និងអ្នកប្រាជ្ញធំឬអ្នកមានឫទ្ធិតេជខ្លាំងក្លា។ សព្វថ្ងៃនៅប្រើចំពោះសង្ឃ ឧទាហរណ៍៖ បពិត្រកម្តែងសង្ឃទាំងឡាយ។

**ប៉ាធ** = 巴馳

ទំនងជាគ្រាប់តាមសម្លេងអ្នកស្រុកដើមហៅថា ប៉ាគូរ។ លោក Pelliot បញ្ជាក់ថា សព្វថ្ងៃជនជាតិចារាយ នៅប្រើពាក្យប៉ាគូរហៅឪពុកនៅឡើយ។

**ប៉ានឃាប ឬ ប៉ានឃិត** = 班詰

ទំនងជាគ្រាប់តាមសម្លេងខ្មែរ បណ្ឌិត (ដែលយើងអានក្លាយទៅបន្ទិត ឬ អន្ទិត) សំដៅយកពពួកអ្នកប្រាជ្ញ។

**ប៉ាវឡេងកាក** = 包稜角

តាមសេចក្តីក្នុងអត្ថបទ លោកជីវតាក្វាន់ ហៅសម្គាល់អង្ករ។ មកពីពាក្យអង្ករ បុរាណយើងហៅ រង្គរ មានប្រើក្នុងសិលាចារឹកជាច្រើន។

**ប៉ាស៊ីវិ** = 八思惟

សំស្ក្រឹត បស្វី ប្រែជាអ្នកមានតបៈ គឺខ្មែរបុរាណហៅពពួកអ្នកបួសជាតាបសនៅតាមព្រៃ ច្រើនអ្នកប្រតិបត្តិតាមគម្ពីរវេទ (សូមមើលក្នុងរឿងរាមកេរ្តិ៍ខ្មែរ) គេប្រើពាក្យនេះ សម្រាប់ពួកយក្សហៅព្រះរាម ដែលទៅធ្វើតបៈក្នុងព្រៃថា បស្វី។

**ផេងកេស៊ុ** = 朋牙四

លោកជីវតាក្វាន់ថា ផេងកេស៊ុ ជារុក្ខជាតិដែលគេយកស្លឹកវាមកធ្វើស្រា។ យើងបានប្រទះឃើញក្នុងវចនានុក្រមខ្មែរភាគ ១ ទំព័រ ៨២៩ និយាយថាខ្មែរយើងជាន់ដើមគេយកស្លឹកឈើម្យ៉ាងមកធ្វើស្រាហៅថា ស្លឹកភ្វាស។
ភ្វាសនេះជាឈើព្រៃ មានសំបកក្រមរគ្រើមៗ ស្លឹកល្អិត រឹង ផ្កាល្អិតកញ្ចុំ ពណ៌ស្វាយ។ ដូច្នេះគឺស្លឹក ភ្វាសនេះហើយដែលកត់តាមសម្លេងចិនទៅជាផេងកេស៊ុ។

**ពុឡៃ** = 孛賴

សំស្ក្រឹត ព្រះ ប្រែថាប្រសើរ គឺតាមនិយមខ្មែរសម្រាប់ហៅបុគ្គលជាទីគោរព មានព្រះពុទ្ធអង្គជាដើម។ ក្រោយមក គេហៅមន្ត្រីមានសក្តិខ្ពស់ឬសង្ឃដែលមានសមណសក្តិ។

**ពូឡូវ ឬពូឡូឈឹង** = 半路村

មកពីពាក្យផ្លូវ ដែលចិនគ្មានសម្លេងអក្សរតម្រួត ក៏អានទៅជាពីរព្យាង្គថា ពូឡូវ។ ឯពាក្យឈិង ជាពាក្យចិន ប្រែថាភូមិ ដូច្នេះពាក្យនេះមានន័យថា ភូមិផ្លូវ ទំនងជា "ភូមិផ្លូវត្រី" សព្វថ្ងៃទេដឹង ? ព្រោះអត្ថបទនេះ និយាយពីភូមិនៅមាត់ទន្លេសាប តាមរយៈដំណើរទៅសៀមរាប។

**ភុយឡាំង** = 皮蘭

លោក Pelliot លោកពន្យល់ពាក្យនេះថា: C'est le nom d'une barque faite d'une seule pièce de bois ; l'original, pilan? piran n'est pas connu។ ចំពោះយើងយល់ថា ទំនងជាទូកកំរោល ដែលគេលុងធ្វើពីឈើមួយដើម ប៉ុន្តែមិនដឹងជាឈ្មោះដើមថា ម៉េច បានជាចិនកត់ជាពាក្យហៅ ភុយឡាំង នេះ។

**ម៉ៃ ឬមី** = 米

ជាពាក្យសម្រាប់មនុស្សស្រីឬសម្រាប់ហៅម្ដាយ ដែលចិនខំថាតាមសម្លេងខ្មែរ មេ។ ឧទាហរណ៍មេជ្រូក មេគោ មេបា ...។

**សាមប៉ា** = 三罷

ចិនអានតាមសម្លេងខ្មែរថា សំពះ។

**ស៊ីនណា** = 新拏

លោក Pelliot ដាក់ក្នុងវង់ក្រចកឲ្យអានថា Siennja ហើយលោកពន្យល់ន័យថា L'original de ce nom de bateau, quelque chose comme senda, n'a pas été retrouvé។ តាមមតិយើង គឺជាទូកមួយយ៉ាងដែលគេយកបន្ទះក្តារមកវាយភ្ជាប់ភ្ជិតគ្នា គេច្រើនហៅសព្វថ្ងៃថា ទូកឡើងក្ដារ បុរាណហៅថា ទូកសណ្ដរ។ ទំងជា "សណ្ដរ" នេះហើយ ដែលចិនកត់ទៅជាស៊ីនណា។

**ស៊ិឡាក់ទី** = 鮮辣的

មកពីពាក្យសំស្ក្រឹត ស្រិស្ទិនឬស្រិស្ទី ប្រែថា អ្នកទ្រទ្រង់នូវស្រុតិ គឺពួកអ្នកចេះដឹងឬអ្នកមានប្រាជ្ញា។

**ហ៊ុតឈឹង** = 佛村

ពាក្យនេះ មកពីភាសាចិន ៖ ហ៊ុត = ព្រះពុទ្ធ + ឈឹង = (ភូមិព្រះពុទ្ធ)។ លោក Pelliot យល់ថាជា ភូមិពោធិសត្វ ប៉ុន្តែបើតាមកំណាព្យលោក សុត្តន្តប្រីជាឥន្ទ "និរាសអង្គរវត្ត" លោកនិយាយពីដំណើរលោកទៅអង្គរវត្តតាមមាត់ទន្លេសាបឃើញភូមិមួយនៅពាក់កណ្ដាលផ្លូវនេះឈ្មោះថា ភូមិត្រៃភព។ ហើយគាត់ពិចារណាថា នរណាយកពាក្យត្រៃភពមកដាក់ឈ្មោះភូមិ ត្បិតពាក្យត្រៃភព ជានាមរបស់ព្រះពុទ្ធដែរ។ ដូច្នេះ ហ៊ុតឈឹង គឺជាភូមិត្រៃភពនោះឯង។